# ស្តង់ដាជាតិសកម្មភាពមីនកម្ពុជា

## ជំពូក ២១

## ស្តីពី

# ការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌក្រឿងផ្ទុះ

# មាតិកា

**សេចក្តីផ្តើម**..........................................................................................................៥
**១. វិសាលភាព** ........................................................................................................៦
**២. វាក្យសព្ទ និង និយមន័យ**............................................................................................៦
**៣. ស្ថានភាពទូទៅនៃ** EORE .............................................................................................៧
៣.១. អ្វីទៅជា EORE ...................................................................................................៧
៣.២. សមាសភាគសំខាន់ៗនៃ EORE ....................................................................................៧
**៤. តួនាទីរបស់** EORE **ក្នុងសកម្មភាពមីន** ...................................................................................៨
៤.១. ការផ្តល់សារសុវត្ថិភាព.................................................................................................៩
៤.២. ការប្រមូលទិន្នន័យពីសហគមន៍មានការគំរាមកំហែង..............................................................៩
៤.៣. ទំនាក់ទំនងសហគមន៍ ..............................................................................................១០
៤.៤. **EORE** គាំទ្រដល់ការស្រាវជ្រាវ ការដាក់ស្លាកសញ្ញា ការបោសសម្អាត និងការកម្ទេចគ្រាប់...................១០
៤.៥. **EORE** គាំទ្រដល់កិច្ចសង្គ្រោះជនពិការ.......................................................................១១
៤.៦. **EORE** គាំទ្រការតស៊ូមតិ.........................................................................................១២
៤ ៧. ពិនិត្យតាមដានគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ......................................................១២
**៥.ការអនុវត្តគោលការណ៍ណែនាំ** EORE ...............................................................................១២
៥.១. ឧបករណ៍ទ្រឹស្តីនៃការផ្លាស់ប្តូរ (ToC) ..........................................................................១២
៥.២. ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ.....................................................................១៣
៥.៣. សមាហរណកម្ម.......................................................................................................១៤
៥.៤. ការចូលរួមរបស់សហគមន៍ និងការផ្តល់សិទ្ធិអំណាច...............................................................១៤
៥.៥. ការគ្រប់គ្រងព័ត៌មាន.................................................................................................១៤
៥.៦. ការកំណត់គោលដៅសមស្រប.........................................................................................១៥
៥.៧. សុវត្ថិភាពបុគ្គលិក **EORE**.........................................................................................១៥
៥.៨. និរន្តរភាពនៃ **EORE**..............................................................................................១៥
**៦.ការប្រមូលទិន្នន័យ និងការវាយតម្លៃគម្រោងការ**.....................................................................១៦
៦.១. ការវាយតម្លៃគម្រោងការ និងគោលការណ៍.........................................................................១៧
៦.២. ការប្រមូលទិន្នន័យ....................................................................................................១៨
**៧.ការរៀបចំផែនការ**.......................................................................................................១៩

**៨. ការបង្កើត និងផ្តល់សារអប់រំ EORE** ........ ១៩
៨.១. ការបង្កើតសារអប់រំ EORE ........ ២១
៨.២. ការសាកល្បងប្រើប្រាស់សារអប់រំ EORE ........ ២១
៨ ៣. ការពិនិត្យ និងកែសម្រួលសារអប់រំ EORE ឡើងវិញ ........ ២២
៨.៤. ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ និងសម្ភារ ........ ២២
**៩. ការអនុវត្ត** ........ ២២
៩.១. EORE ក្នុងស្ថានភាពបន្ទាន់ ........ ២២
៩.២. ការអនុវត្ត EORE នៅតាមសាលារៀន ........ ២៣
**១០. ការត្រួតពិនិត្យ និងវាយតម្លៃ** ........ ២៣
១០.១. ការត្រួតពិនិត្យវឌ្ឍនភាពនៃ EORE ........ ២៣
១០.២. ការបង្កើតប្រព័ន្ធត្រួតពិនិត្យ ........ ២៥
១០.៣. សកម្មភាពកែតម្រូវ ........ ២៥
១០.៤. ការវាយតម្លៃ ........ ២៦
**១១. ការអភិវឌ្ឍសមត្ថភាព** ........ ២៧
១១.១. បង្កើតផែនការអភិវឌ្ឍសមត្ថភាព ........ ២៧
១១.២. សហគមន៍ដែលមានហានិភ័យ ........ ២៧
១១.៣. អាជ្ញាធរមីន ........ ២៨
១១.៤. ប្រតិបត្តិករ EORE ........ ២៨
**១២. ប័ណ្ណទទួលស្គាល់ស្ថាប័ន និងអាជ្ញាប័ណ្ណប្រតិបត្តិការ** ........ ២៨
**១៣. តួនាទី និងការទទួលខុសត្រូវ** ........ ២៨
១៣.១. អាជ្ញាធរមីន ........ ២៨
១៣.២.ប្រតិបត្តិករ EORE ........ ២៩
ឧបសម្ព័ន្ធ ក ........ ៣៣
ឧបសម្ព័ន្ធ ខ ........ ៣៨
ឧបសម្ព័ន្ធ គ ........ ៤៣

## អក្សរសម្គាល់

| | |
|---|---|
| APMBC | អនុសញ្ញាស្តីពីការហាម ការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និង ការបំផ្លាញចោលគ្រាប់មីន |
| AMS | រដ្ឋសមាជិកអាស៊ាន |
| BLS | ការស្រាវជ្រាវមូលដ្ឋាន |
| CBMRR | កម្មវិធីកាត់បន្ថយគ្រោះថ្នាក់មីនតាមសហគមន៍ |
| CBURR | កម្មវិធីកាត់បន្ថយគ្រោះថ្នាក់យុទ្ធភណ្ឌមិនទាន់ផ្ទុះតាមសហគមន៍ |
| CCW | អនុសញ្ញាសព្វាវុធធម្មតា |
| CMAA | អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន |
| CMAS | ស្តង់ដារសកម្មភាពកំចាត់មីនកម្ពុជា |
| CMRES | ស្តង់ដារអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម |
| CMVIS | ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីននៅកម្ពុជា |
| CRC | កាកបាទក្រហមកម្ពុជា |
| CRPD | អនុសញ្ញាស្តីពីសិទ្ធិជនពិការ |
| DAC | ក្រុមប្រឹក្សាសកម្មភាពជនពិការ |
| EO | យុទ្ធភណ្ឌគ្រឿងផ្ទុះ |
| EOD | ក្រុមកម្ទេចយុទ្ធភណ្ឌមិនទាន់ផ្ទុះ |
| ERW | សំណល់ជាតិផ្ទុះពីសង្គ្រាម |
| IMAS | ស្តង់ដារសកម្មភាពកំចាត់មីនអន្តរជាតិ |
| IMSMA | ប្រព័ន្ធគ្រប់គ្រងព័ត៌មានវិស័យមីន |
| ISO | ស្តង់ដារអាយអេសអូ |
| MACC | គណកម្មាធិការសម្របសម្រួលសកម្មភាពកំចាត់មីន |
| MAPU | អង្គភាពផែនការសកម្មភាពមីនខេត្ត |
| MoH | ក្រសួងសុខាភិបាល |
| MRE | ការអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម |
| NCDM | គណកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| NMAS | ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន |
| PMAC | គណកម្មាធិការសកម្មភាពកំចាត់មីនខេត្ត |
| QA | ការធានាគុណភាព |
| QC | ការត្រួតពិនិត្យគុណភាព |

| | |
|---|---|
| QM | ការគ្រប់គ្រងគុណភាព |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SOP | បទដ្ឋានប្រតិបត្តិការ |
| TRG | ក្រុមការងារបច្ចេកទេស |
| TWG-MA | ក្រុមការងារបច្ចេកទេសចម្រុះរាជរដ្ឋាភិបាល-ដៃគូអភិវឌ្ឍលើវិស័យមីន |
| UN | អង្គការសហប្រជាជាតិ |
| UNICEF | អង្គការយូនីសេហ្វ |

## សេចក្តីផ្តើម

ការអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (MRE) បានចាប់ផ្តើមនៅកម្ពុជាក្នុងឆ្នាំ១៩៩៣ ដែលជាផ្នែកមួយនៃសកម្មភាពមីនមនុស្សធម៌ដើម្បីដោះស្រាយបញ្ហាមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម។ ក្នុងឆ្នាំ២០១២ អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ដោយមានការពិគ្រោះយោបល់ជាមួយប្រតិបត្តិករអប់រំមីន ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធនានា បានបង្កើតស្តង់ដារជាតិស្តីពីការអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមនៅកម្ពុជា (CMRES) ដើម្បីផ្តល់ការណែនាំអំពីការអនុវត្ត MRE ។

ការខិតខំប្រឹងប្រែងរួមគ្នាក្នុងវិស័យសកម្មភាពមីន បានធ្វើឲ្យចំនួនជនរងគ្រោះធ្លាក់ចុះពី ៤ ៣២០នាក់ ក្នុងឆ្នាំ១៩៩៦ មកនៅត្រឹមចំនួន ៦៥នាក់ ក្នុងឆ្នាំ២០២០។ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាមីន/គ្រាប់នៅតែបន្តការគំរាមកំហែងខ្ពស់ ដែលទាមទារការប្តេជ្ញាចិត្តបន្ថែមពីរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍។ ហេតុដូច្នេះ MRE នៅតែជាសមាសធាតុដ៏សំខាន់មួយក្នុងផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន (NMAS) ២០១៨-២០២៥ ។

ចាប់ពី CMRES ត្រូវបានអនុម័តដាក់ឲ្យប្រើប្រាស់ ការងារ MRE មានការផ្លាស់ប្តូរ ផ្អែកទៅតាមបរិបទនៃការគំរាមកំហែង មូលហេតុគ្រោះថ្នាក់ គ្រោះធម្មជាតិ នវានុវត្តន៍ និងបច្ចេកវិទ្យាថ្មីៗ ដែលជានិន្នាការសកល។ ដូច្នេះ កម្ពុជាត្រូវធ្វើការកែលម្អ CMRES ដើម្បីបង្កើនប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការការងារ MRE ។

ការកែសម្រួល CMRES ដើម្បីអនុលោមតាមស្តង់ដារសកម្មភាពកំចាត់មីនអន្តរជាតិជំពូក ១២.១០ (IMAS 12.10) ស្តីពីការអប់រំគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះដែលបានកែសម្រួលលើកទី២ក្នុងខែកញ្ញា ឆ្នាំ២០២០ ហើយពាក្យយុទ្ធភណ្ឌគ្រឿងផ្ទុះ(EO) រួមបញ្ចូលទាំងមីន និងគ្រាប់។ ដូច្នេះ CMRES បានកែសម្រួលឲ្យទៅជា "ស្តង់ដារជាតិស្តីពីការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ (EORE)"។ ស្តង់ដារនេះ បានបង្កើតឡើងដោយផ្អែកលើបទពិសោធន៍ និងជំនាញដែលទទួលបានពីការអនុវត្ត EORE ជាច្រើនឆ្នាំនៅកម្ពុជា ក៏ដូចជារបាយការណ៍វាយតម្លៃការអនុវត្ត MRE ២០១៣-២០១៩ របស់អង្គការយូនីសេហ្វ និងអាជ្ញាធរមីន វិធីសាស្ត្ររួមក្នុងការអនុវត្តការងារ EORE ក្នុងរដ្ឋសមាជិកអាស៊ានរបស់មជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន (ARMAC) និងផែនការសកម្មភាពអូស្លូ ២០២០-២០២៤ ហើយស្របទៅនឹងស្តង់ដារជាតិជំពូកផ្សេងទៀត។

ស្តង់ដារនេះនឹងមានការពិនិត្យកែសម្រួលជារៀងរាល់បីឆ្នាំម្តង ប៉ុន្តែការកែសម្រួលអាចធ្វើឡើងក្នុងពេលណាមួយក្នុងរយៈកាលកំណត់នេះ ប្រសិនបើមានហេតុផលសមស្របផ្អែកលើលក្ខខណ្ឌសុវត្ថិភាព និងប្រសិទ្ធភាពកិច្ចប្រតិបត្តិការ ឬគោលបំណងវិចារណកថា។

## ការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

### ១.វិសាលភាព

ស្តង់ដារនេះដាក់ចេញនូវគោលការណ៍ និងការណែនាំឲ្យមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងព័ត៌មាន ការសិក្សាវាយតម្លៃ ការរៀបចំផែនការ ការអនុវត្ត និងការត្រួតពិនិត្យវាយតម្លៃលើ EORE ។ ប្រតិបត្តិករអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ត្រូវបង្កើត និងអនុវត្តបទដ្ឋានប្រតិបត្តិការរបស់ខ្លួនអនុលោមតាមស្តង់ដារនេះ ក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរមីន។ ស្តង់ដារនេះ ផ្តល់នូវក្របខ័ណ្ឌការងារថ្នាក់ជាតិសម្រាប់ប្រតិបត្តិការ EORE នៅកម្ពុជា និងរួមចំណែកក្នុងការសម្រេចបាន NMAS ២០១៨-២០២៥ ហើយជំនួសឲ្យ CMRES មុន។

### ២. វាក្យសព្ទ និង និយមន័យ

ពាក្យគន្លឹះ និងពាក្យដែលប្រើញឹកញាប់នៅក្នុងស្តង់ដារនេះមានរៀបរាប់ដូចខាងក្រោម៖

**ត្រូវតែ** ត្រូវបានប្រើដើម្បីបញ្ជាក់ពីតម្រូវការចាំបាច់ វិធីសាស្ត្រ ឬភាពជាក់លាក់ ដែលត្រូវអនុវត្តឲ្យស្របទៅនឹងស្តង់ដារសកម្មភាពកំចាត់មីនកម្ពុជា។

**គួរតែ** ត្រូវបានប្រើដើម្បីបញ្ជាក់អំពីតម្រូវការ វិធីសាស្ត្រ ឬភាពជាក់លាក់ផ្សេងៗទៀតដែលបានស្នើឡើង។

**អាច** ត្រូវបានប្រើដើម្បីបញ្ជាក់ពីវិធី ឬមធ្យោបាយដែលអាចទទួលយកបាន។

**យុទ្ធភណ្ឌគ្រឿងផ្ទុះ** (EO) គ្រាប់ដែលមានផ្ទុករំសេវផ្ទុះ រួមមាន មីន គ្រាប់បែកចង្កោម គ្រាប់មិនទាន់ផ្ទុះ គ្រាប់ដែលបោះបង់ចោល ខ្សែអន្ទាក់បង្កៃ គ្រាប់កែច្នៃ និងគ្រាប់ផ្សេងៗទៀត (ដូចបានកំណត់ក្នុងវិសោធនកម្មពិធីសារ II នៃអនុសញ្ញាសព្វាវុធជម្មតា)។

**ការអប់រំអំពីគ្រោះថ្នាក់យុទ្ធភណ្ឌគ្រឿងផ្ទុះ** (EORE) គឺជាសកម្មភាពនានា ដែលធ្វើឡើងដើម្បីកាត់បន្ថយគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ តាមរយៈការលើកកម្ពស់ការអប់រំយល់ដឹងដល់ស្ត្រី ក្មេងស្រី ក្មេងប្រុស និងបុរស ទៅតាមសកម្មភាពងាយរងគ្រោះផ្សេងៗ តួនាទី និងតម្រូវការរបស់ជនងាយរងគ្រោះ ដើម្បីជំរុញឲ្យមានការផ្លាស់ប្តូរឥរិយាបថ។

**ប្រតិបត្តិករអប់រំអំពីគ្រោះថ្នាក់យុទ្ធភណ្ឌគ្រឿងផ្ទុះ** (EORE Operator) រួមមាន ស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ដែលទទួលខុសត្រូវក្នុងការអនុវត្តគម្រោង EORE។ ប្រតិបត្តិករ EORE អាចជាអ្នកម៉ៅការ អ្នកម៉ៅការបន្ត អ្នកពិគ្រោះយោបល់ ឬភ្នាក់ងារផ្សេងៗ។

**ក្រុមអប់រំអំពីគ្រោះថ្នាក់យុទ្ធភណ្ឌគ្រឿងផ្ទុះ** ជាផ្នែកមួយនៃអង្គភាព ដែលអនុវត្តសកម្មភាព EORE រួមមាន ការវាយតម្លៃតម្រូវការ គម្រោងកម្មវិធីផ្សព្វផ្សាយសាធារណៈ គម្រោងអប់រំនៅតាមសាលារៀន ឬ គម្រោងអប់រំនិងទំនាក់ទំនងនៅសហគមន៍។

**ជនរងគ្រោះប្រយោល** សំដៅលើសមាជិកគ្រួសារ និងសហគមន៍ដែលបានអ្នកស្លាប់ ឬរងរបួសដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ រួមទាំងសហគមន៍ដែលរងផលប៉ះពាល់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះផងដែរ។

**គម្រោង** សំដៅលើសកម្មភាពទាំងឡាយណា ដែលមានគោលដៅ ពេលវេលាកំណត់ និងផែនការសកម្មភាពជាក់លាក់ ។ ដើម្បីសម្រេចគោលដៅគម្រោងឲ្យបានជោគជ័យ ចាំបាច់ត្រូវកំណត់តម្រូវការធនធានច្បាស់លាស់ មុនពេលចាប់ផ្តើមគម្រោង ។

**កម្មវិធី** ជាបណ្តុំសកម្មភាពរយៈពេលមធ្យម ឬ វែង របស់អង្គភាពមួយដើម្បីសម្រេចចក្ខុវិស័យ និងគោលដៅយុទ្ធសាស្ត្រ ។ កម្មវិធីសកម្មភាពមីន ឬ កម្មវិធី EORE មួយមានគម្រោងសកម្មភាពជាច្រើនសម្រាប់គាំទ្រ ។

## ៣. **ស្ថានភាពទូទៅនៃ** EORE

### ៣.១. អ្វីទៅជា EORE

EORE ជាសសរស្តម្ភមួយនៃសសរស្តម្ភទាំងប្រាំក្នុងសកម្មភាពមីនមនុស្សធម៌រួមមាន ការបោសសម្អាត ការអប់រំអំពីគ្រោះថ្នាក់ដោយយុទ្ធភណ្ឌគ្រឿងផ្ទុះ ការជួយសង្គ្រោះជនពិការ ការតស៊ូមតិ និងការកម្ទេចគ្រាប់ក្នុងឃ្លាំង។ ការអនុវត្ត EORE ត្រូវស្របតាមគោលការណ៍ស្នូលមនុស្សធម៌៖ មនុស្សជាតិ អព្យាក្រឹតភាព តម្លាភាព និងឯករាជ្យភាព។ ដូចដែលបានកំណត់នៅក្នុងវាក្យសព្ទ និងនិយមន័យខាងលើ EORE គឺជាដំណើរការកាត់បន្ថយគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដល់ប្រជាពលរដ្ឋ ទ្រព្យសម្បត្តិ និងបរិស្ថាន តាមរយៈការផ្លាស់ប្តូរឥរិយាបថរបស់ស្ត្រី កុមារី កុមារា និងបុរសក្នុងសហគមន៍ដែលរងផលប៉ះពាល់ ។

ដោយមានការឯកភាពរួមក្នុងវិស័យសកម្មភាពមីន រវាងបណ្តារដ្ឋសមាជិកអាស៊ាន និងសកលលោក សកម្មភាព EORE (បើអាចធ្វើទៅបាន) គួរត្រូវបានដាក់បញ្ចូលក្នុងការងារមនុស្សធម៌ ការអភិវឌ្ឍន៍ ការការពារ ការអប់រំ ក៏ដូចជាដំណើរការការស្រាវជ្រាវ ការបោសសម្អាត ការកម្ទេចគ្រាប់ និងកិច្ចសង្គ្រោះជនពិការ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋដែលងាយរងគ្រោះ។

### ៣.២. សមាសធាតុសំខាន់ៗនៃ EORE

សកម្មភាព EORE ដែលអនុវត្តនៅកម្ពុជាមាន ៣ ផ្នែកសំខាន់ៗគឺ:

ក) **ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ៖** ជាផ្នែកមួយដ៏សំខាន់នៃសកម្មភាព EORE ដោយផ្តោតលើការផ្តល់ព័ត៌មាន កាត់បន្ថយគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ តាមរយៈលើកកម្ពស់ការយល់ដឹងពីគ្រោះថ្នាក់ដល់បុគ្គល និងសហគមន៍ ហើយធ្វើឡើងក្នុងទម្រង់

នៃការផ្សព្វផ្សាយ ការផ្តល់ព័ត៌មាន និងការណែនាំដែលចាំបាច់នានាតាមរយៈសារពត៌មាន បណ្តាញសង្គម កម្មវិធីទូរស័ព្ទ ដែលធ្វើឲ្យចំណេញពេលវេលា និងចំណាយថវិកាតិច។

ខ) **ការអប់រំ និងការបណ្តុះបណ្តាលៈ** គឺផ្តោតលើសកម្មភាពទាំងឡាយណា ដែលមានគោលបំណងកាត់បន្ថយគ្រោះថ្នាក់ដែលបង្កបង្កបួសស្នាមដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ តាមរយៈលើកកម្ពស់ការយល់ដឹងពីគ្រោះថ្នាក់ដល់បុគ្គល និងសហគមន៍ និងជំរុញឲ្យមានការផ្លាស់ប្តូរឥរិយាបថ និងវិធីសាស្ត្រនៃការចូលរួមរបស់សហគមន៍ ក្នុងការផ្ទេរ និងទទួលយកចំណេះដឹង អាកប្បកិរិយា និងការអនុវត្តតាមរយៈការបង្រៀន និងការរៀន។ សកម្មភាពទាំងនេះអាចនិងធ្វើតាមបែបផ្លូវការ និងមិនផ្លូវការ។

គ) **ទំនាក់ទំនងសហគមន៍ និងវិធីសាស្ត្រមានការចូលរួមពីសហគមន៍ៈ** ជាប្រព័ន្ធ និងដំណើរការក្នុងការចែករំលែកព័ត៌មានរវាងអាជ្ញាធរមីន ប្រតិបត្តិករ និងសហគមន៍រងផលប៉ះពាល់ពីការរកឃើញយុទ្ធភណ្ឌគ្រឿងផ្ទុះ និងបញ្ហាប្រឈម។ ទំនាក់ទំនងសហគមន៍ គឺជាការចូលរួមពីក្រុមពាក់ព័ន្ធខាងក្រៅក្នុងការសម្របសម្រួលជាមួយសហគមន៍។ វិធីសាស្ត្របែបសហគមន៍អាចជួយបណ្តុះបណ្តាលសមាជិកសហគមន៍(ភូមិ ឃុំ ស្រុក) ឲ្យមានសមត្ថភាពក្នុងការអប់រំបន្តនៅសហគមន៍របស់ខ្លួន។ វិធីសាស្ត្រទាំងពីរនេះអាចធ្វើឲ្យសហគមន៍ៈ

(១) ចូលរួមយ៉ាងពេញលេញក្នុងសកម្មភាពមីន និងសកម្មភាពអប់រំ EORE។

(២) ផ្តល់ព័ត៌មានជូនអាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករសកម្មភាពមីន អំពីទីតាំង ទំហំ និងផលប៉ះពាល់ នៃតំបន់មានការសង្ស័យ។

(៣) បង្កើតឲ្យមានប្រព័ន្ធរាយការណ៍ជាមួយអង្គភាពផែនការសកម្មភាពមីនខេត្ត (ម៉ាពូ) ប្រតិបត្តិករសកម្មភាពមីន ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ និងអាជ្ញាធរមូលដ្ឋាន។

(៤) ធ្វើឲ្យមានការអភិវឌ្ឍសមស្រ និងមានយុទ្ធសាស្ត្រកាត់បន្ថយគ្រោះថ្នាក់ក្នុងមូលដ្ឋាន។

(៥) ជំរុញ និងពង្រឹងសមត្ថភាពមូលដ្ឋាន និងធនធាន ដើម្បីឆ្លើយតប និងដោះស្រាយបញ្ហានៅក្នុងសហគមន៍។

(៦) ធានាថាសកម្មភាពមីន ឆ្លើយតបនឹងតម្រូវការជាអាទិភាពរបស់សហគមន៍។

## ៤. **តួនាទីរបស់** EORE **ក្នុងសកម្មភាពមីន**

ជាទូទៅ EORE មានទំនាក់ទំនងជាមួយសកម្មភាពមីនផ្សេងៗទៀត ពីព្រោះវាកើតឡើងនៅក្នុងតំបន់ដែលមានគ្រោះថ្នាក់ និងការគំរាមកំហែងខ្ពស់ ។ ដើម្បីទទួលបានលទ្ធផលល្អ កម្មវិធីសកម្មភាពមីន ត្រូវប្រមូលទិន្នន័យជាច្រើន ដើម្បីធ្វើការចាត់អាទិភាពក្នុងការប្រើប្រាស់ធនធានមនុស្ស និងបច្ចេកទេស ។ ជំនួសឲ្យការរក្សាទុកទិន្នន័យប្រតិបត្តិការតែក្នុងស្ថាប័នខ្លួន ព័ត៌មានសំខាន់ៗគួរតែចែករំលែក ដើម្បីផ្តល់អត្ថប្រយោជន៍ដល់ស្ថាប័នដទៃ។ ប្រសិនជាអាច ភាគីពាក់ព័ន្ធគួរធានាថា សកម្មភាព EORE បានបញ្ចូលទៅក្នុងសកម្មភាពមីនផ្សេងទៀត ។

## ៤.១. ការផ្តល់សារសុវត្ថិភាព

ការផ្តល់សារសុវត្ថិភាព ផ្តោតលើព័ត៌មាន និងសកម្មភាពអប់រំ ដើម្បីកាត់បន្ថយការស្លាប់ និងរបួសដែលបង្កដោយយុទ្ធភណ្ឌគ្រឿងផ្ទុះ តាមរយៈការលើកកម្ពស់ការយល់ដឹងពីគ្រោះថ្នាក់ដល់បុគ្គល និងសហគមន៍ តាមរយៈការជំរុញអោយមានឥរិយាបថសុវត្ថិភាព។ ការបង្កើតឲ្យមានសារអប់រំ និងសម្ភារផ្សេងៗ គួរផ្អែកលើការប្រមូលព័ត៌មាន និងវិភាគទិន្នន័យដោយមានការបែងចែកតាម អាយុ ភេទ និងប្រភេទនៃគ្រោះថ្នាក់។ សារអប់រំគួរផ្សព្វផ្សាយតាមរបៀបខាងក្រោមនេះ៖

ក) ការទំនាក់ទំនងពីបុគ្គលទៅបុគ្គល ការប្រជុំភូមិ កម្មវិធីសិក្សាតាមសាលា ប្រព័ន្ធផ្សព្វផ្សាយខ្នាតតូច (ផ្ទាំងរូបភាពខ្នាតតូចធំ អាវយឺត ខិតប័ណ្ណ) ប្រព័ន្ធផ្សព្វផ្សាយសាធារណៈ (ទូរទស្សន៍ វិទ្យុ និងកាសែត) និងបណ្តាញសង្គម (Facebook, WhatsApp និង Telegram)។

ខ) ក្នុងករណីមានគ្រោះមហន្តរាយកើតឡើង ត្រូវពិគ្រោះយោបល់ជាមួយអាជ្ញាធរមីន និងស្ថាប័នពាក់ព័ន្ធ ដើម្បីឆ្លើយតបទៅនឹង EORE និងការដោះមីន។

## ៤.២. ការប្រមូលទិន្នន័យពីសហគមន៍មានការគំរាមកំហែង

គួរប្រមូលទិន្នន័យពីសហគមន៍ដែលមានការគំរាមកំហែង និងទីតាំងផ្សេងទៀតដែលមានការសង្ស័យផលប៉ះពាល់នៃយុទ្ធភណ្ឌគ្រឿងផ្ទុះ មកលើប្រជាពលរដ្ឋ រួមបញ្ចូលទាំងទិន្នន័យជនរងគ្រោះ និងករណីគ្រោះថ្នាក់ ព្រមទាំងសកម្មភាព ឬការបំលាស់ទីរបស់ប្រជាពលរដ្ឋ។

គួរបែងចែកទិន្នន័យជនរងគ្រោះតាមលក្ខណៈរបួសស្នាម (របួស ស្លាប់) ដោយបែងចែក៖ ភេទ អាយុ ពិការភាព ទីតាំងគ្រោះថ្នាក់ ពេលវេលា មូលហេតុ និងទីកន្លែងគ្រោះថ្នាក់ សកម្មភាពដែលបង្កគ្រោះថ្នាក់ ប្រភេទយុទ្ធភណ្ឌគ្រឿងផ្ទុះ(បើស្គាល់) មានចំណេះដឹងអំពីគ្រោះថ្នាក់ពីមុន ធ្លាប់ទទួលបានការអប់រំពីឥរិយាបថសុវត្ថិភាព ធ្លាប់ទទួលបានជំនួយជនរងគ្រោះ និងតម្រូវការសេដ្ឋកិច្ច-សង្គម។

ទិន្នន័យគួរត្រូវបានប្រើប្រាស់ដើម្បី៖

ក) យល់កាន់តែច្បាស់អំពីទំហំនៃការគំរាមកំហែង និងផលប៉ះពាល់។

ខ) កំណត់ក្រុមគោលដៅ រួមមានឥរិយាបថមិនមានសុវត្ថិភាព និងហេតុផលសម្រាប់ការប្រថុយប្រថាន។

គ) ប្រាប់ពីរបៀបនៃការរៀបចំ ការចាត់អាទិភាព ការអនុវត្ត និងការត្រួតពិនិត្យលើសកម្មភាពអប់រំ EORE ឲ្យបានគ្រប់គ្រាន់។

ឃ) គាំទ្រសកម្មភាពមីន និងសកម្មភាពផ្សេងៗទៀត។

### ៤.៣. ទំនាក់ទំនងសហគមន៍

ទំនាក់ទំនងសហគមន៍សំដៅលើដំណើរការចែករំលែកទៅវិញទៅមកនូវព័ត៌មាន គំនិតយោបល់ និងចំណេះដឹង ដោយប្រើឧបករណ៍ទំនាក់ទំនង និងវិធីសាស្ត្រជាច្រើនដើម្បីជួយឲ្យតួអង្គសកម្មភាពមីន រួមមាន អាជ្ញាធរមីន ប្រតិបត្តិករ ម៉ាពូ និងសហគមន៍ យល់ដឹងឲ្យកាន់តែប្រសើរឡើង អំពីសហគមន៍ដែលរងផលប៉ះពាល់ ធនធានដែលមានស្រាប់ តម្រូវការ និងការចាត់អាទិភាព ។ វិធីសាស្ត្រនេះមានគោលបំណងដូចខាងក្រោម៖

ក) ធ្វើឲ្យសហគមន៍ អាជ្ញាធរមូលដ្ឋាន និងភ្នាក់ងារអភិវឌ្ឍន៍ យល់ដឹងអំពីសកម្មភាពមីន និងចូលរួមក្នុងសកម្មភាព EORE ការស្រាវជ្រាវ ការដាក់ស្លាកសញ្ញា ការបោសសម្អាត ការកម្ទេចយុទ្ធភណ្ឌគ្រឿងផ្ទុះ និងកិច្ចសង្គ្រោះជនពិការ។

ខ) សម្រួលដល់ការផ្លាស់ប្តូរព័ត៌មានរវាងតួអង្គសកម្មភាពមីន។

គ) ជួយបង្កើតយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យស្របតាមបរិបទជាក់ស្តែង។

ឃ) ធានាថាសមាជិកសហគមន៍រួមមាន ស្ត្រី កុមារី កុមារា បុរស និងជនជាតិភាគតិច បានដឹងពីការគំរាមកំហែងនិងចូលរួមកំណត់ហានិភ័យ តម្រូវការ និងការចាត់អាទិភាពនៅក្នុងសកម្មភាពមីន។

ការទំនាក់ទំនងសហគមន៍ អនុវត្តដោយក្រុម EORE ឬដោយក្រុមសកម្មភាពមីន។ បុគ្គលិកទំនាក់ទំនងសហគមន៍ គួរទទួលបានការបណ្តុះបណ្តាល ការបំពាក់សម្ភារ និងមានសមត្ថភាពគ្រប់គ្រាន់។ គ្រប់ក្រុមទំនាក់ទំនងសហគមន៍ គួរមានសមភាពយេនឌ័រ។

### ៤.៤. EORE គាំទ្រដល់ការស្រាវជ្រាវ ការដាក់ស្លាកសញ្ញា ការបោសសម្អាត និងការកម្ទេចគ្រាប់

EORE គួរគាំទ្រដល់សកម្មភាពស្រាវជ្រាវ ដាក់ស្លាកសញ្ញា បោសសម្អាត និងកម្ទេចគ្រាប់ ក៏ដូចជាជំរុញឲ្យសហគមន៍គាំទ្រដល់សកម្មភាពទាំងនេះ។

នៅក្នុងការស្រាវជ្រាវមិនបច្ចេកទេស (NTS) និងការស្រាវជ្រាវបច្ចេកទេស (TS) ប្រតិបត្តិករ EORE គួរផ្អែកលើទិន្នន័យ/ព័ត៌មាន ដែលផ្តល់ដោយសហគមន៍ ឬ អ្នកផ្តល់ព័ត៌មាន៖

ក) កំណត់អត្តសញ្ញាណប្រភេទ EO។

ខ) រួមចំណែកក្នុងការកំណត់ទីតាំងគំរាមកំហែងជាក់លាក់នៃ EO។

គ) ជួយឲ្យសហគមន៍យល់ដឹង និងចូលរួមក្នុងការសម្រេចចិត្តអំពីការកាត់បន្ថយផ្ទៃដីតាមរយៈការស្រាវជ្រាវមិនបច្ចេកទេស (ការលុបចេញ/ការទន្រ្ទានប្រើប្រាស់) និងតាមរយៈការស្រាវជ្រាវបច្ចេកទេស។

ឃ) យល់ដឹងអំពីផលប៉ះពាល់នៃ EO ដល់ជីវិត និងសុខមាលភាពរបស់សហគមន៍។

ង) កត់ត្រាព័ត៌មានអំពីការចាត់អាទិភាពរបស់សហគមន៍ក្នុងការបោសសម្អាត។

នៅក្នុងការងារដាក់ស្លាកសញ្ញា ប្រតិបត្តិករ EORE គួរៈ
ក) ប្រមូលព័ត៌មាន និងផ្សព្វផ្សាយអំពីស្លាកសញ្ញាបំរាមក្នុងសហគមន៍។
ខ) ធានាថាសហគមន៍មានការយល់ដឹង និងគោរពចំពោះស្លាកសញ្ញាបំរាម និងរបាំងការពារចម្ការមីន/ EO។
គ) កត់ត្រាព័ត៌មានអំពីការដាក់ស្លាកសញ្ញាទៅលើតំបន់អាទិភាពរបស់សហគមន៍ (រួមមានសម្ភារសមស្របដែលការពារបានពីការដកចោល លួច ឬបំផ្លាញចោល)។

ក្នុងការងារបោសសម្អាត ប្រតិបត្តិករ EORE គួរៈ
ក) រក្សាទំនាក់ទំនងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករសកម្មភាពមីន។
ខ) ជូនដំណឹងសហគមន៍អំពីវត្តមាននៃក្រុមសកម្មភាពមីន។
គ) ជូនដំណឹងដល់សហគមន៍អំពីនីតិវិធីសុវត្ថិភាព ដែលត្រូវប្រើក្នុងអំឡុងពេលប្រតិបត្តិការបោសសម្អាត។
ឃ)ជូនដំណឹងដល់ស្ត្រី ក្មេងស្រី ក្មេងប្រុស និងបុរស អំពីតំបន់បានបោសសម្អាតរួច និងតំបន់នៅមានការគំរាមកំហែង រួមទាំងផ្លាកសញ្ញានៃតំបន់បោសសម្អាតរួច និងមិនទាន់បោសសម្អាតរួច។
ង) រួមចំណែកក្នុងការផ្ទេរ-ប្រគល់ និងផ្តល់ទំនុកចិត្តដល់សហគមន៍អំពីសុវត្ថិភាពដីដែលបានបោសសម្អាតរួច។
ច) តាមដាន និងវាយតម្លៃការប្រើប្រាស់ដីដែលបានរំដោះរួច និងជំរុញសហគមន៍ឲ្យប្រើប្រាស់។

ក្នុងការងារកម្ទេចគ្រាប់យុទ្ធភណ្ឌមិនទាន់ផ្ទុះ (EOD) ប្រតិបត្តិករ EORE គួរៈ
ក) រក្សាទំនាក់ទំនងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករសកម្មភាពមីន។
ខ) ប្រមូល និងរាយការណ៍ព័ត៌មានអំពីគ្រាប់ជូនក្រុម EOD។
គ) សម្រួលដល់ការងារក្រុម EOD នៅក្នុងសហគមន៍ដើម្បីយកគ្រាប់ចេញ និងកម្ទេចចោល។

## ៨.៥. EORE គាំទ្រដល់កិច្ចសង្គ្រោះជនពិការ

កិច្ចសង្គ្រោះជនពិការសំដៅលើសកម្មភាពផ្តល់ដំណោះស្រាយលើតម្រូវការ និងសិទ្ធិជនរងគ្រោះ រួមទាំងការប្រមូលទិន្នន័យ សេវាសង្គ្រោះបន្ទាន់ សេវាសុខាភិបាល ស្តារកាយនីតិសម្បទា គាំទ្រផ្នែកចិត្តសាស្ត្រ សេដ្ឋកិច្ចសង្គម ច្បាប់ និងគោលនយោបាយ។

ប្រតិបត្តិករ EORE គួរៈ
ក) កំណត់អត្តសញ្ញាណជនរងគ្រោះ រួមបញ្ចូលជនរស់រានមានជីវិត ជនរងគ្រោះដោយប្រយោល និងជនមានពិការភាពផ្សេងៗទៀត ដែលត្រូវការជំនួយនិងណែនាំពួកគេទៅកន្លែងផ្តល់សេវា។

ខ) រួមចំណែកក្នុងការប្រមូលទិន្នន័យសង្គ្រោះជនពិការដោយសារ EO និងប្រព័ន្ធបញ្ជូនជនរងគ្រោះ រួមមានទិន្នន័យអំពីសមត្ថភាពស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់កិច្ចសង្គ្រោះជនពិការ ។

គ) ទំនាក់ទំនងជាមួយមជ្ឈមណ្ឌលស្តារនីតិសម្បទា (មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងអ្នកផ្តល់សេវាដទៃទៀត ដើម្បីធានាថាសេវាត្រូវបានផ្តល់ជូន។

ឃ) ប្រសិនបើចាំបាច់ សម្របសម្រួលការដឹកជញ្ជូនដល់ជនរងគ្រោះ និងសមាជិកគ្រួសារទៅមន្ទីរពេទ្យ ឬមណ្ឌលសុខភាព ដើម្បីទទួលការព្យាបាល និងជូនត្រឡប់មកវិញ។

ង) ប្រសិនបើអាច គួរពិចារណាផ្តល់ការងារសមស្របដល់អ្នករស់រានមានជីវិត ជាអ្នកសម្របសម្រួល EORE ។

### ៤.៦. EORE គាំទ្រការតស៊ូមតិ

ប្រតិបត្តិករ EORE គួរដើរតួនាទីក្នុងការកសាងឆន្ទៈនយោបាយនៅក្នុងប្រទេសកម្ពុជាតាមរយៈយន្តការសម្របសម្រួលរបស់អាជ្ញាធរមីន។ ការតស៊ូមតិគាំទ្រដល់:

ក) អនុសញ្ញាស្តីពីការហាមការប្រើប្រាស់មីនប្រឆាំងមនុស្សនិងអនុសញ្ញាស្តីពីសព្វាវុធចង្កោម។

ខ) អនុសញ្ញាស្តីពីសិទ្ធិជនពិការរបស់អង្គការសហប្រជាជាតិ (UNCRPD) និងច្បាប់ស្តីពីការការពារ និងលើកកម្ពស់សិទ្ធិជនពិការនៅកម្ពុជា។

### ៤.៧. ពិនិត្យតាមដានគ្រោះថ្នាក់ដោយសារ EO

ព័ត៌មានស្តីពីគ្រោះថ្នាក់/ឧប្បត្តិហេតុដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ មានសារៈសំខាន់សម្រាប់ប្រើប្រាស់ក្នុងការធ្វើផែនការ ការអនុវត្ត ការត្រួតពិនិត្យ និងវាយតម្លៃការងារ EORE និងសកម្មភាពមីនផ្សេងទៀតប្រកបដោយប្រសិទ្ធភាព។ អាជ្ញាធរមីនគ្រប់គ្រងប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីននៅកម្ពុជា ដោយប្រមូលនិងផ្សព្វផ្សាយទិន្នន័យគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះនៅកម្ពុជា។ ម្យ៉ាងវិញទៀត វិធីសាស្ត្រដែលមានលក្ខណៈជាប្រព័ន្ធវិភាគ និងបកស្រាយអំពីយេនឌ័រ និងអាយុ គួរតែបង្កើតឡើងដើម្បីកំណត់អត្តសញ្ញាណជនងាយរងគ្រោះ ទម្រង់ព្យាករណ៍ និងកត្តាហានិភ័យ។

## ៥. ការអនុវត្តគោលការណ៍ណែនាំ EORE

គ្រប់ប្រតិបត្តិការ EORE ត្រូវអនុវត្តតាមគោលការណ៍ណែនាំដូចខាងក្រោម:

### ៥.១. ឧបករណ៍ទ្រឹស្តីនៃការផ្លាស់ប្តូរ (ToC)

ឧបករណ៍ទ្រឹស្តីនៃការផ្លាស់ប្តូរ ជាវិធីសាស្ត្រថ្មីមួយនៅក្នុងការងារសកម្មភាពមីនមនុស្សធម៌ដែលអនុលោមតាមឧបករណ៍ក្របខ័ណ្ឌការងារ (Logframe) ដែលមានស្រាប់ និងជាតម្រូវការម្ចាស់

ជំនួយ។ វិធីសាស្ត្រទាំងពីរនេះគួរត្រូវបានប្រើប្រាស់បំពេញគ្នាទៅវិញទៅមក ជាជាងប្រើដាច់ដោយឡែកពីគ្នា។

ឧបករណ៍ទ្រឹស្តីនៃការផ្លាស់ប្តូរសម្រាប់ EORE ត្រូវបានសង្ខេបដូចតទៅ៖

- ប្រសិនបើប្រជាពលរដ្ឋទទួលបានការអប់រំ ហើយពួកគាត់យល់ដឹងពីខ្លឹមសារ ដូច្នេះពួកគាត់នឹងទទួលបានចំណេះដឹងបន្ថែមអំពីគ្រោះថ្នាក់។
- ប្រសិនបើពួកគាត់ប្រើប្រាស់ចំណេះដឹងបន្ថែមនេះ ដើម្បីប្រកាន់យកឥរិយាបថសុវត្ថិភាព ដូច្នេះអត្រាគ្រោះថ្នាក់នឹងកាត់បន្ថយ។

គ្រប់អង្គភាពពាក់ព័ន្ធការងារ EORE គួរតែបង្ហាញឧបករណ៍ទ្រឹស្តីនៃការផ្លាស់ប្តូរ (ToC) ដើម្បីពិពណ៌នាអំពីរបៀបអនុវត្តសកម្មភាព ឬអន្តរាគមន៍ ដើម្បីបង្កើតលទ្ធផលរយៈពេលខ្លី មធ្យម និងវែង។ ឧបករណ៍ទ្រឹស្តីនៃការផ្លាស់ប្តូរសម្រាប់ការងារ EORE ត្រូវតែជាក់លាក់ គ្រប់ជ្រុងជ្រោយ និងអាចសមាហរណកម្មជាមួយសកម្មភាពមីនផ្សេងៗ។ ឧបករណ៍ទ្រឹស្តីនៃការផ្លាស់ប្តូរគួរត្រូវបានបង្កើតឡើងតាមរយៈដំណើរការនៃការចូលរួមផ្តល់យោបល់ ជាជាងកំណត់ពីថ្នាក់លើទៅថ្នាក់ក្រោម។ ឧបករណ៍នេះអាចត្រូវបានបង្កើតឡើងសម្រាប់គម្រោង កម្មវិធី គោលនយោបាយ និងផែនការយុទ្ធសាស្ត្រ។

## ៩.២. ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ

ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងវិស័យសកម្មភាពមីន គួរមានកិច្ចសហប្រតិបត្តិការ និងសម្របសម្រួលជានិច្ចឲ្យបានការបំពេញបន្ថែមរវាងកម្មវិធី វិធីសាស្ត្រ និងសារអប់រំ ដើម្បីជៀសវាងការអនុវត្តការងារត្រួតស៊ីគ្នា និងបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន ឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍ ផែនការអភិវឌ្ឍន៍ជាអាទិភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងផ្សេងៗទៀត។

កម្រិតនៃការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ អាចមាន៖

ក) អន្តរជាតិ៖ APMBC, CCW, CRPD និងកិច្ចប្រជុំសកម្មភាពមីនមនុស្សធម៌របស់អង្គការសហប្រជាជាតិ។

ខ) ក្នុងតំបន់៖ ARMAC និងយន្តការអាស៊ានផ្សេងទៀត។

គ) ថ្នាក់ជាតិ៖ ក្រុមការងារបច្ចេកទេសចម្រុះរាជរដ្ឋាភិបាល-ដៃគូអភិវឌ្ឍលើវិស័យមីន (TWG-MA), គណកម្មាធិការសម្របសម្រួលសកម្មភាពកំចាត់មីន (MACC), ក្រុមការងារបច្ចេកទេស (TRG) និងគណកម្មាធិការសកម្មភាពកំចាត់មីនខេត្ត (PMAC)/អង្គភាពផែនការសកម្មភាពមីនខេត្ត (MAPU)។

## ៩.៣. សមាហរណកម្ម

ដើម្បីធានាបាននូវប្រសិទ្ធភាព និងប្រសិទ្ធផលនៃប្រតិបត្តិការ EORE គួរតែធ្វើសមារណកម្ម EORE ជាមួយសកម្មភាពមីន និងវិស័យផ្សេងទៀត។ ការធ្វើសមាហរណកម្មនេះ អាជ្ញាធរមីន និង ប្រតិបត្តិករ EORE គួរៈ

- ក) ធានាថាផែនការសកម្មភាពការងារ EORE បានរួមចំណែកក្នុងការសម្រេចបាននូវផែនការយុទ្ធសាស្រ្តជាតិសកម្មភាពមីន ឆ្នាំ ២០១៨-២០២៥ ស្របតាមអាទិភាពនៃការអភិវឌ្ឍន៍ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ខ) សមាហរណកម្ម EORE ជាមួយនឹងសកម្មភាពមីនផ្សេងទៀត។
- គ) បន្តគាំទ្រ និងពង្រីកការធ្វើសមាហរណកម្មEORE ជាមួយជីវភាពរស់នៅរបស់សហគមន៍។
- ឃ)បន្តបញ្ជ្រាប EORE ក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា។
- ង) គួរធ្វើសមាហរណកម្ម EORE ជាមួយនឹងកម្មវិធីផ្សេងទៀតដូចជា កម្មវិធីសុខុមាលភាព កម្មវិធីអភិវឌ្ឍន៍ កម្មវិធីមនុស្សធម៌ និងកម្មវិធីកីឡា និងវិស័យឯកជន។ ដូច្នេះវិស័យសកម្មភាពមីនត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយវិស័យផ្សេងទៀត ដើម្បីធានាថា EORE ត្រូវបានអនុវត្តតាមរយៈស្ថាប័នផ្សេងៗក្រៅពីសកម្មភាពមីន។

## ៩.៤. ការចូលរួមរបស់សហគមន៍ និងការផ្តល់សិទ្ធិអំណាច

ប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍ ដែលទទួលរងផលប៉ះពាល់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ គឺជាភាគីពាក់ព័ន្ធដ៏សំខាន់ ដែលទទួលបានការផ្តល់សិទ្ធអំណាចចូលរួមផ្តល់យោបល់ ដើម្បីដំណើរការកសាងគម្រោង និងសកម្មភាព EORE។

ប្រតិបត្តិករ EORE គួរធានាថាសមាជិកសហគមន៍ រួមទាំងស្រ្តី ក្មេងស្រី ក្មេងប្រុស បុរស និង ជនជាតិភាគតិចបានចូលរួមក្នុងការកសាងផែនការ ការអនុវត្ត ការតាមដាន និងការវាយតម្លៃគម្រោង EORE ។

## ៩.៥. ការគ្រប់គ្រងព័ត៌មាន

ការគ្រប់គ្រង និងអនុវត្តការងារ EORE ប្រកបដោយប្រសិទ្ធភាព តម្រូវឲ្យមានព័ត៌មានជាក់លាក់ គ្រប់គ្រាន់ និងទាន់ពេលវេលា។ ប្រភពព័ត៌មានជាច្រើនដែលអាចប្រមូលបានពីថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីវិភាគការធ្វើផែនការ អនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃការងារ EORE។ សកម្មភាពខាងក្រោមគួរត្រូវបានពិចារណាៈ

- ក) ប្រតិបត្តិករ EORE ត្រូវផ្តល់របាយការណ៍ទៀងទាត់ដល់អាជ្ញាធរមីនសម្រាប់ការបញ្ចូលទិន្នន័យ EORE ទៅក្នុងប្រព័ន្ធទិន្នន័យថ្នាក់ជាតិ។

ខ) ទិន្នន័យ CMVIS គួរតែត្រូវបានប្រើដោយប្រតិបត្តិករ EORE ដើម្បីកែសម្រួលស្រប តាមប្រភេទនៃគ្រោះថ្នាក់ ដោយការប្រមូលធនធានសម្រាប់ការឆ្លើយតបប្រកបដោយ ប្រសិទ្ធភាព និងទាន់ពេលវេលាដល់សហគមន៍ដែលរងផលប៉ះពាល់។

## ៨.៦. ការកំណត់គោលដៅសមស្រប

EORE គួរតែមានបរិបទជាក់លាក់ ឆ្លើយតបតម្រូវការ អាទិភាពផ្សេងៗ វប្បធម៌ និងបែបបទប្រពៃណីតាមតំបន់ រួមមាន ស្ត្រី កុមារី កុមារា និងបុរស នៅក្នុងសហគមន៍ដែលរងផលប៉ះពាល់។ ប្រតិបត្តិករ EORE គួរតែ៖

ក) ជានាថាទិន្នន័យនៃទំហំផលប៉ះពាល់ពីការគំរាមកំហែង គ្រោះថ្នាក់ សកម្មភាពជីវភាពរស់នៅ និងស្ថានភាពសេដ្ឋកិច្ចសង្គម ត្រូវបានប្រើប្រាស់ដើម្បីកំណត់ទីតាំង វិធីសាស្ត្រ និងសារអប់រំ នៃការងារ EORE ។

ខ) កំណត់តំបន់ និងក្រុមដែលមានហានិភ័យខ្ពស់។

គ) រិះរកមធ្យោបាយផ្សេងៗ ដើម្បីទៅដល់ជនគោលដៅដែលពិបាកជួបផ្តល់សារអប់រំ EORE ដូចជា បុរស (ធ្វើការឆ្ងាយៗ) និងក្មេងក្រៅសាលា។

## ៨.៧. សុវត្ថិភាពបុគ្គលិក EORE

តម្រូវការសុវត្ថិភាពសម្រាប់បុគ្គលិក EORE ត្រូវរៀបចំឡើងដោយអនុលោមតាមស្តង់ដារជំពូកលេខ ០៩ "តម្រូវការសុវត្ថិភាព និង សុខុមាលភាពវិជ្ជាជីវៈ - តម្រូវការទូទៅ" ។ ប្រតិបត្តិករ EORE ត្រូវជានាបុគ្គលិក៖

ក) ទទួលវគ្គបណ្តុះបណ្តាលយល់ដឹងអំពីយុទ្ធភណ្ឌគ្រឿងផ្ទុះ មុនពេលបញ្ជូនទៅធ្វើការនៅតំបន់ដែលរងផលប៉ះពាល់។

ខ) យល់ដឹងពីប្រព័ន្ធស្លាកសញ្ញា(មីន/គ្រាប់) ដែលបានប្រើប្រាស់នៅកម្ពុជាទាំងផ្លូវការ និងមិនផ្លូវការ។

គ) ធ្វើសកម្មភាព EORE លើទីតាំងដែលមានសុវត្ថិភាព។

ឃ)អនុវត្តតាមការណែនាំរបស់ប្រធានការដ្ឋានបោសសម្អាតអំឡុងពេលទស្សនកិច្ចចម្ការមីន/គ្រាប់។

ង) កុំប៉ះពាល់យុទ្ធភណ្ឌគ្រឿងផ្ទុះ។

## ៨.៨. និរន្តរភាពនៃ EORE

និរន្តរភាពនៃ EORE មានន័យថា សហគមន៍ដែលរងផលប៉ះពាល់រួមមាន ស្ត្រី កុមារី កុមារា និងបុរសបន្តទទួលបានសារអប់រំ EORE និងប្រកាន់ខ្ជាប់នូវឥរិយាបថប្រកបដោយសុវត្ថិភាព។ ដើម្បីសម្រេចគោលដៅនេះ ប្រតិបត្តិករ EORE គួរធានាថា៖

- រាជរដ្ឋាភិបាលត្រូវមានភាពជាម្ចាស់ពេញលេញលើសកម្មភាព EORE ។
- មានការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ដូចមានចែងក្នុងផ្នែក៥.២ និងសមាហរណកម្ម ដូចមានចែងក្នុងផ្នែក ៥.៣ ខាងលើ។
- ប្រព័ន្ធរាយការណ៍ និងកត់ត្រាការកម្ទេចយុទ្ធភណ្ឌមិនទាន់ផ្ទុះ ត្រូវបង្កើតឡើងដើម្បីទទួល និងឆ្លើយតបទៅនឹងសំណើរបស់សហគមន៍។
- ច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។
- បណ្តាញ EORE តាមសហគមន៍(ឧទាហរណ៍ៈ កម្មវិធីកាត់បន្ថយគ្រោះថ្នាក់មីនតាមសហគមន៍ (CBMRR) និងកម្មវិធីកាត់បន្ថយគ្រោះថ្នាក់គ្រាប់មិនទាន់ផ្ទុះតាមសហគមន៍ (CBURR)) ត្រូវបានពង្រីក និងថែរក្សា។
- សហគមន៍ងាយរងគ្រោះ (ស្ត្រី កុមារី កុមារា និងបុរស) និងក្រុមជនជាតិភាគតិចគួរត្រូវបានឲ្យចូលរួមពីដំបូង និងគ្រប់ដំណាក់កាលនៃគម្រោងដើម្បីធានានូវផលប៉ះពាល់កាន់តែច្រើនឡើង និងនិរន្តរភាពអន្តរាគមន៍ EORE។
- វិធីសាស្ត្រ EORE គួរតែត្រូវបានកែសម្រួលឲ្យល្អប្រសើរសម្រាប់ឆ្ពោះទៅរកកម្ពុជាមួយគ្មានមីនឆ្នាំ២០២៥ និងដោះស្រាយការគំរាមកំហែងដែលនៅសេសសល់។

## ៦.ការប្រមូលទិន្នន័យ និងការវាយតម្លៃតម្រូវការ

គោលបំណងនៃការប្រមូលទិន្នន័យ និងការវាយតម្លៃអំពីតម្រូវការ ដើម្បីកំណត់ វិភាគ និងចាត់អាទិភាព គ្រោះថ្នាក់នៅក្នុងសហគមន៍ វាយតម្លៃសមត្ថភាព និងភាពងាយរងគ្រោះរបស់ស្ត្រី កុមារី កុមារា បុរសក្នុងសហគមន៍ រួមទាំងជនជាតិភាគតិច និងជនគោលដៅដែលពិបាកទៅជួបផ្តល់សារអប់រំ EORE ។ អាជ្ញាធរមីន និងប្រតិបត្តិករ EORE គួរផ្អែកលើការវាយតម្លៃអំពីតម្រូវការ ដែលមានការបញ្ចូលការគិតគូរពីទិដ្ឋភាពយេនឌ័រ និងទិដ្ឋភាពផ្សេងៗទៀត។ ការប្រមូលទិន្នន័យ និងការវាយតម្លៃតម្រូវការសម្រាប់សកម្មភាព EORE ផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់កសាងផែនការ និងកម្មវិធី ដែលអាចអនុវត្ត តាមដាន និងវាយតម្លៃប្រកបដោយប្រសិទ្ធភាព។

ការប្រមូលទិន្នន័យ និងការវាយតម្លៃពីតម្រូវការអាចត្រូវបានធ្វើឡើងនៅថ្នាក់ជាតិ និងសម្របសម្រួលដោយអាជ្ញាធរមីន ឬ ដោយប្រតិបត្តិករនៅក្នុងតំបន់គោលដៅជាក់លាក់។ បុគ្គលិកទទួលបន្ទុកក្នុងការប្រមូលទិន្នន័យ និងការវាយតម្លៃអំពីតម្រូវការ ត្រូវទទួលបានការបណ្តុះបណ្តាលរួមទាំងក្រមសីលធម៌ និងគោលការណ៍មនុស្សធម៌ ក្នុងការអនុវត្តសកម្មភាពទាំងនេះ។

## ៦.១. ការវាយតម្លៃតម្រូវការ និងគោលការណ៍

ការវាយតម្លៃតម្រូវការ នឹងផ្តល់ព័ត៌មានចាំបាច់សម្រាប់ធ្វើការសម្រេចចិត្តលើគោលដៅ វិសាលភាព និងលទ្ធផលនៃគម្រោង EORE ។ ទោះបីជាការវាយតម្លៃតម្រូវការត្រូវធ្វើមុនការរៀបចំផែនការ និងការអនុវត្តសកម្មភាព EORE វាមិនមែនជាសកម្មភាពដែលធ្វើតែមួយលើកទេ ប៉ុន្តែជាសមាសធាតុដ៏សំខាន់នៃការគ្រប់គ្រងវដ្តគម្រោង EORE ។ ផែនការវាយតម្លៃតម្រូវការដែលមានប្រសិទ្ធិភាពគួរបញ្ជាក់៖

ក) គោលបំណងនៃការប្រមូលទិន្នន័យ។

ខ) ទិន្នន័យអ្វីខ្លះដែលចាំបាច់ត្រូវប្រមូល។

គ) របៀបប្រមូលទិន្នន័យ និងប្រភព (ឧទាហរណ៍៖ ជម្រើសនៃវិធីសាស្ត្រប្រមូលទិន្នន័យ តំបន់គ្របដណ្តប់ ការជ្រើសរើស និងអ្នកផ្តល់ព័ត៌មានសំខាន់ៗ)។

ឃ) អ្នកណាគួរប្រមូលទិន្នន័យ និងវគ្គបណ្តុះបណ្តាលអ្វីខ្លះដែលត្រូវផ្តល់ជូន។

ង) ពេលវេលាដែលត្រូវប្រមូលទិន្នន័យ។

ច) មធ្យោបាយប្រមូល ពិនិត្យផ្ទៀងផ្ទាត់ និងរក្សាទុកទិន្នន័យ។ ល។

ដើម្បីធានាបាននូវការប្រមូលទិន្នន័យ និងការវាយតំលៃតម្រូវការឲ្យបានត្រឹមត្រូវ ត្រូវមានគោលការណ៍ដូចខាងក្រោម៖

ក) ប្រតិបត្តិករ EORE អាចប្រមូលទិន្នន័យដោយប្រើប្រាស់ទម្រង់របាយការណ៍ផ្ទៃក្នុង។

ខ) ត្រូវបញ្ជាក់ប្រភពដើមនៃទិន្នន័យដែលយកមកប្រើប្រាស់។

គ) ប្រតិបត្តិករ EORE មិនត្រូវផ្តល់ការរំពឹងទុកដែលមិនអាចអនុវត្តបាន។ ឧទាហរណ៍៖ សន្យាថា បន្ទាប់ការវាយតម្លៃពីតម្រូវការនេះនឹងមានការបោសសម្អាតជូន។

ឃ)ភាពខុសគ្នានៃតម្រូវការស្ត្រី កុមារី កុមារា និងបុរស គួរតែត្រូវបានពិចារណា។ ការយល់ឃើញ និងតម្រូវការរបស់សមាជិកសហគមន៍អាចខុសគ្នា យោងទៅតាមអាយុ ភេទ ពិការភាព សេដ្ឋកិច្ចសង្គម ជាតិសាសន៍ សាសនា ការអប់រំ និងទីប្រជុំជន/ជនបទជាដើម ។ ល។

ង) ស្ថានភាពគ្រោះថ្នាក់ គួរតែត្រូវបានអនុវត្តចំពោះជនគោលដៅ មានចំនួន៥ប្រភេទ៖ មិនបានយល់ដឹង (unaware) មិនបានទទួលព័ត៌មាន (uninformed) យល់ខុសព័ត៌មាន (misinformed) រឹងរូស (reckless) និងគ្មានជម្រើស (forced) ដើម្បីជួយដល់ការបង្កើតសម្ភារឧបទេ្ទស មាតិកាសារអប់រំ វិធីសាស្ត្រនៃការផ្តល់សារអប់រំនិងវិធីសាស្ត្ររួមគ្នាដែលធ្វើឲ្យមានការផ្លាស់ប្តូរឥរិយាបថជនគោលដៅ ក្នុងការកាត់បន្ថយគ្រោះថ្នាក់។

ច) ប្រតិបត្តិករ EORE គួរបង្កើនការយល់បានច្បាស់ពីវិធីសាស្ត្រដោះស្រាយ តាមរយៈក្រុមពិភាក្សា(FGD) ដើម្បីទទួលបានមតិត្រឡប់ រួមមាន សិក្សាគ្រប់ជ្រុងជ្រោយអំពីឥរិយាបថរបស់ប្រជាពលរដ្ឋដែលរស់នៅជុំវិញតំបន់គំរាមកំហែង។

ឆ) ប្រតិបត្តិករ EORE គួរប្រើប្រាស់វិធីសាស្ត្រប្រមូលព័ត៌មានតាមបែបចូលរួម (PRA) ដើម្បីកំណត់មធ្យោបាយដោះស្រាយដោយសហគមន៍ ដែលអាចចែករំលែកពីម្នាក់ទៅម្នាក់ក្នុងសហគមន៍ដទៃទៀត។

ជ) អ្នករស់រានមានជីវិតពីយុទ្ធភណ្ឌគ្រឿងផ្ទុះ មានសិទ្ធិឯកជនភាពដែលត្រូវរាប់បញ្ចូលក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងកម្មវិធីដែលពាក់ព័ន្ធដល់ពួកគេ។ សិទ្ធិទាំងនេះគួរតែត្រូវបានគោរពគ្រប់ពេលវេលា។

ឈ) ប្រតិបត្តិករ EORE ដែលត្រូវធ្វើការវាយតម្លៃតម្រូវការ EORE ត្រូវបញ្ជូនទិន្នន័យមកអាជ្ញាធរមីនតាមការស្នើសុំ ដោយរក្សាការសម្ងាត់ ឬគិតគូរអំពីក្រមសីលធម៌ផ្សេងទៀត។

## ៦.២. ការប្រមូលទិន្នន័យ

ប្រតិបត្តិករ EORE គួរធានាថាទិន្នន័យដែលប្រមូលបាន មានការគិតគូរអំពីភេទ អាយុ ពិការភាព និងតម្រូវការផ្សេងៗ វប្បធម៌ និងបទពិសោធន៍របស់ស្ត្រី កុមារី កុមារ និងបុរស និងក្រុមជនជាតិភាគតិចនៅក្នុងសហគមន៍ដែលរងផលប៉ះពាល់។ ក្រុមប្រមូលទិន្នន័យសម្រាប់ការវាយតម្លៃតម្រូវការគួរទទួលបានការបណ្តុះបណ្តាល បំពាក់សម្ភារសមស្រប និងមានសមាជិកចម្រុះភេទ។ ការប្រមូលទិន្នន័យគួរកំណត់ដូចខាងក្រោម៖

ក) ក្រុមគោលដៅ រួមបញ្ចូលក្រុមប្រឈមគ្រោះថ្នាក់ខ្ពស់ សង្គមនិងភូមិសាស្ត្រ នរណាជាអ្នកប្រថុយប្រថាន ប្រភេទសកម្មភាពប្រថុយប្រថាន ពេលណា និងមូលហេតុ(អាចពាក់ព័ន្ធតួនាទីយេនឌ័រនៅក្នុងសង្គម) និងអ្នករងផលប៉ះពាល់ដោយយុទ្ធភណ្ឌគ្រឿងផ្ទុះ (ជាពិសេស យកចិត្តទុកដាក់ចំពោះសកម្មភាពមនុស្សចូលក្នុងទៅក្នុងតំបន់មានគ្រោះថ្នាក់)។

ខ) ទិន្នន័យមូលដ្ឋាន និងទិន្នន័យប្រៀបធៀបលើចំណេះដឹងនៃគ្រោះថ្នាក់យុទ្ធភណ្ឌគ្រឿងផ្ទុះ អាកប្បកិរិយា ជំនឿ ទំនៀមទំលាប់ យន្តការដោះស្រាយ និងប្រភពព័ត៌មានអំពីគ្រោះថ្នាក់ EO និងសុវត្ថិភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាន។

គ) ព័ត៌មានមូលដ្ឋានស្តីពីការគំរាមកំហែងយុទ្ធភណ្ឌគ្រឿងផ្ទុះ (ឧទាហរណ៍៖ ប្រភេទគ្រាប់ លក្ខណៈទីតាំងតំបន់សង្ស័យដែលគ្រាប់ទាំងនោះបានជួបប្រទះ ស្លាកសញ្ញាផ្លូវការ និងមិនផ្លូវការដែលបានប្រើប្រាស់ ។ល។)

ឃ) តំបន់ដែលរងផលប៉ះពាល់ខ្លាំង (ប្រមូលទិន្នន័យពីកន្លែងដែលមនុស្សរងរបួស សកម្មភាពនៅពេលមានគ្រោះថ្នាក់ កន្លែងមានហានិភ័យខ្ពស់បំផុត កន្លែងដែលឥរិយាបថប្រថុយប្រថានកំពុងកើតមាន ។ ល។)

ង) សារអប់រំ EORE ប្រើប្រាស់ផ្អែកតាមក្រុមគោលដៅ (វាយតម្លៃទៅលើស្ថានភាពរបួស និងទង្វើប្រថុយប្រថាន។

ច) វិធីសាស្ត្រដែលនាំឲ្យប្រជាពលរដ្ឋផ្លាស់ប្តូរឥរិយាបថ។

ឆ) ការប្រមូលព័ត៌មានជាទៀងទាត់ពីការផ្លាស់ប្ដូរឥរិយាបថ ឧទាហរណ៍ រយៈពេលពី៦ខែ ទៅ ១២ខែ បន្ទាប់ពីការផ្ដល់សារអប់រំដំបូងដោយប្រើកម្រងសំណួរដដែលទៅមនុស្សដដែល។

ជ) មធ្យោបាយទំនាក់ទំនងទៅក្រុមគោលដៅដើម្បីផ្ដល់សារអប់រំ។

ឈ)សហការជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូដើម្បីផ្ដល់សារអប់រំ EORE ឬឆ្លើយតបបន្ទាន់។

ញ)ធនធានមនុស្សរួមមាន ថ្នាក់ដឹកនាំមូលដ្ឋាន សមាជិកសំខាន់ៗតំណាងសហគមន៍ អ្នកដែលអាចជួយដល់ការងារ EORE ។

ដ) ពេលវេលាសម្រាប់អនុវត្តគម្រោង (ប្រមូលទិន្នន័យអំពីប្រភេទ និងទំហំបញ្ហាយុទ្ធភណ្ឌគ្រឿងផ្ទុះ និងប៉ាន់ប្រមាណពេលវេលាសម្រាប់ដោះស្រាយនូវផលប៉ះពាល់) ។

## ៧.ការរៀបចំផែនការ

ការរៀបចំផែនការ EORE គួរតែធ្វើឡើងជាទម្រង់ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិការ ហើយជាផ្នែកមួយនៃដំណើរការរៀបចំផែនការសកម្មភាពមីនទាំងមូល។ ដំណាក់កាលរៀបចំផែនការគួរតែមានការចូលរួមពីដៃគូ និងភាគីពាក់ព័ន្ធ។

នៅក្នុងបរិបទប្រទេសកម្ពុជា ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន (NMAS) ជាផែនការយុទ្ធសាស្ត្រ ។ ផែនការសកម្មភាពការងារ គឺជាផែនការប្រតិបត្តិការដែលបង្កើតឡើងដោយអាជ្ញាធរមីន និងការមានចូលរួមពីប្រតិបត្តិករ និងភាគីពាក់ព័ន្ធ។ ប្រតិបត្តិករ EORE ត្រូវរៀបចំផែនការសកម្មភាពការងាររបស់ខ្លួន ដើម្បីរួមចំណែកធ្វើឲ្យសម្រេចបាននូវផែនការសកម្មភាពការងារ និងNMAS ។

ដំណើរការរៀបចំផែនការ រួមមានការកំណត់គោលដៅរួមសម្រាប់កម្មវិធី ឬគម្រោង និងបណ្ដុំសកម្មភាព។ សកម្មភាពគួរឆ្លើយតបទៅនឹងគោលដៅដែលបានកំណត់ និងបញ្ជាក់យ៉ាងច្បាស់ពីតម្រូវការធនធាន ព្រមទាំងលទ្ធផលរំពឹងទុក។ សូចនាករ និងមធ្យោបាយផ្ទៀងផ្ទាត់ គួរបង្កើតឡើងសម្រាប់វាស់វែងលទ្ធផល។ ឧបករណ៍ទ្រឹស្ដីនៃការផ្លាស់ប្ដូរ (ToC) គួរប្រើប្រាស់អមជាមួយទម្រង់ក្របខ័ណ្ឌការងារ(Logframe) ។

ការរៀបចំផែនការ ជាដំណើរការដែលត្រូវត្រួតពិនិត្យជាប្រចាំ ដែលវាមិនមែនជាសកម្មភាពដែលធ្វើតែម្ដងចប់នោះទេ ។ អាជ្ញាធរមីនបង្កើតបញ្ជីភូមិអាទិភាពសម្រាប់សកម្មភាព EORE ដោយប្រើលក្ខណៈវិនិច្ឆ័យ រួមមានៈ ទិន្នន័យ CMVIS BLS អត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងទិន្នន័យប្រជាជន។ ប្រតិបត្តិករ EORE ត្រូវរៀបចំផែនការសកម្មភាព EORE ប្រចាំឆ្នាំរបស់ខ្លួនស្របតាមបញ្ជីដែលបានបង្កើតឡើងនេះ។

ប្រសិនបើប្រតិបត្តិករ EORE មានធនធានបន្ថែមសម្រាប់ពង្រីកសកម្មភាព EORE នៅភូមិដទៃទៀត ក្នុងផែនការសកម្មភាពរបស់ខ្លួន ត្រូវស្នើសុំការយល់ព្រមពីអាជ្ញាធរមីន។

## ៨. ការបង្កើត និងផ្តល់សារអប់រំ EORE

សារសុវត្ថិភាព គឺជាចំណុចដ៏សំខាន់នៃគំនិតផ្តួចផ្តើមសកម្មភាពEORE។ ការបង្កើតការផ្សព្វផ្សាយសារសុវត្ថិភាព និងការវាយតម្លៃពីផលរំពឹងទុក ជាលទ្ធផលដែលបានមកពីភាពច្បាស់លាស់នៃផែនការយុទ្ធសាស្ត្រនិងដំណើរការ។

រាល់ការប្រាស្រ័យទាក់ទងនៅក្នុង EORE គួរផ្អែកលើផែនការយុទ្ធសាស្ត្រច្បាស់លាស់ដែលផ្តោតលើក្រុមគោលដៅងាយរងគ្រោះថ្នាក់ ហើយសមស្របទៅតាមសង្គម និងវប្បធម៌។ ការផ្តល់សារអប់រំ EORE ដល់កុមារ គួរប្រើប្រាស់វិធីសាស្ត្រឲ្យស្របជាមួយកុមារ។ ផ្អែកតាមបទពិសោធន៍កម្មវិធី EORE តាមរយៈកម្មវិធីសិក្សានៅសាលា ការនិទានរឿងដែលមានបញ្ចូលនូវសារអប់រំ EORE និងការពង្រឹងឥរិយាបថសុវត្ថិភាព អាចមានប្រយោជន៍សម្រាប់កុមារដែលមានអាយុចន្លោះពី ៥ឆ្នាំ ដល់ ១១ឆ្នាំ។

ប្រតិបត្តិករ EORE គួរប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយឌីជីថលឲ្យបានទូលំទូលាយ រួមមានសារអប់រំតាមទូរស័ព្ទ ឬតាមរយៈកម្មវិធីបណ្តាញសង្គមផ្សេងៗ។

ការបង្កើត និងការផ្តល់សារអប់រំ EORE គួរផ្អែកលើតួនាទីរបស់ស្ត្រីដែលមានស្រាប់ក្នុងសង្គមវប្បធម៌ តាមប្រពៃណីនៅកម្ពុជា ដើម្បីប្រើឥទ្ធិពលរបស់ស្ត្រីជា "ភ្នាក់ងារនៃការផ្លាស់ប្តូរ" ទៅលើឥរិយាបថសុវត្ថិភាពរបស់សមាជិកគ្រួសារដទៃទៀត។ គម្រោង ឬកម្មវិធី EORE មិនគួរសន្មត់ថា ស្ត្រី និងកុមារី ជានិច្ចជាកាលងាយរងគ្រោះនោះទេ ជាក់ស្តែងជនរងគ្រោះ EO កន្លងមកភាគច្រើនជាបុរស និងកុមារា។

ជាអប្បបរមា ក្នុងយុទ្ធសាស្ត្រទំនាក់ទំនង EORE គួរមានបញ្ចូលចំណុចដូចខាងក្រោម៖

ក) ឥរិយាបថប្រថុយប្រថាន ដែលត្រូវដោះស្រាយ។

ខ) មូលហេតុ នៃឥរិយាបថប្រថុយប្រថាន។

គ) ក្រុមគោលដៅ និងតំបន់។

ឃ) ប្រភេទគំរាមកំហែង EO ក្នុងសហគមន៍។

ង) វប្បធម៌សហគមន៍រួមទាំងបទដ្ឋានសង្គម។

ច) សកម្មភាពមីនផ្សេងៗកំពុងអនុវត្ត។

ឆ) សារសុវត្ថិភាពសំខាន់ៗ។

ជ) បណ្តាញទំនាក់ទំនង។

ឈ) មធ្យោបាយនៃការផ្សព្វផ្សាយ។

## ៨.១. ការបង្កើតសារអប់រំ EORE

សារអប់រំដែលត្រូវផ្សព្វផ្សាយអាស្រ័យទៅលើក្រុមគោលដៅ ឥរិយាបថដែលត្រូវកែប្រែ និង កត្តាផ្សេងៗដែលអាចជំរុញក្រុមគោលដៅឲ្យទទួលយកឥរិយាបថសុវត្ថិភាព។ សារអប់រំ ឬនិមិត្តសញ្ញា គួរតែមានលក្ខណៈសមរម្យ ស្របតាមវប្បធម៌ ភាសា និងសង្គម។

គួរផ្តល់សារអប់រំវិជ្ជមាន ដែលប្រជាពលរដ្ឋអាចគិតថា គាត់អាចចូលរួម និងធ្វើឲ្យប្រសើរឡើង នូវការរស់នៅរបស់ខ្លួន និងគ្រួសារ។ សារអប់រំមិនចាំបាច់ខ្លីទេ ប៉ុន្តែវាគួរតែច្បាស់លាស់។

ដើម្បីបង្កើតសារអប់រំ ប្រតិបត្តិករ EORE គួរអនុវត្តដូចខាងក្រោម៖

ក) សារអប់រំដែលបង្កើតថ្មីៗត្រូវស្នើសុំពីអាជ្ញាធរមីន ដើម្បីប្រមូលជាតុចូលពីក្រុមការងារ បច្ចេកទេស EORE (TRG-EORE)។

ខ) បង្កើតសារអប់រំ និងសកម្មភាពជាក់លាក់មានលក្ខណៈជាប្រព័ន្ធ ផ្អែកតាមចំណេះដឹង ឥរិយាបថ និងតម្រូវការរបស់ស្ត្រី កុមារី កុមារា និងបុរស នៃក្រុមងាយរងគ្រោះខ្ពស់។

គ) អនុវត្តតាមគោលការណ៍ "កុំបង្កគ្រោះថ្នាក់" ដើម្បីបង្កើតសារអប់រំដែលមានប្រសិទ្ធភាព បំផុត។

ឃ)និទានអំពីរឿងរ៉ាវផ្ទាល់ខ្លួនរបស់ជនរងគ្រោះណាមួយ ដែលមានការចាប់អារម្មណ៍ និង ចងចាំជាជាងប្រើប្រាស់អង្គហេតុ និងតួលេខ។

ង) ទទួលស្គាល់ និងយល់ពីបញ្ហាប្រឈមរបស់ក្រុមងាយរងគ្រោះ (ឧទាហរណ៍ កត្តាជីវភាព) ជាជាងការណែនាំដែលមិនប្រាកដនិយម ឬទ្រឹស្តីដែលមិនអាចអនុវត្តបាន។

ច) ផលិតសម្ភារអប់រំដែលមានគុណភាពខ្ពស់ អាចមើលឃើញច្បាស់ជាជាងប្រើប្រាស់ ព័ត៌មានដែលមិនសូវទាក់ទាញការយកចិត្តទុកដាក់។

## ៨.២. ការសាកល្បងប្រើប្រាស់សារអប់រំ EORE

រាល់សារអប់រំ និងមធ្យោបាយផ្សព្វផ្សាយត្រូវសាកល្បងមុនពេលដាក់ឲ្យប្រើប្រាស់ ហើយ ការសាកល្បងគួរធ្វើជាមួយតំណាងក្រុមគោលដៅ និងក្រុមជនងាយរងគ្រោះខ្លាំង។ ប្រសិនបើក្រុម គោលដៅរួមមានកសិករជាយុវជននៃជាតិសាសន៍ជាក់លាក់ណាមួយ ការធ្វើតេស្តសាកល្បងដំបូងគួរ ត្រូវបានអនុវត្តជាមួយពួកគេទាំងនេះ។

ការសាកល្បងប្រើប្រាស់ដែលគិតគូរពីភាពខុសគ្នានៃកម្រិតអប់រំ និងភាសា រវាងក្រុមសង្គម ឬ វប្បធម៌ ហើយស្ត្រី កុមារី កុមារា និងបុរស អាចត្រូវបានធ្វើនៅកម្រិតផ្សេងៗពីគ្នា ជាមួយនឹងការ ចំណាយប្រកបដោយប្រសិទ្ធភាព ដោយមិនចាំបាច់ប្រើប្រាស់ពេលយូរ។ គោលបំណងនៃការធ្វើតេស្ត នេះ ដើម្បីធានាថា សារអប់រំ ឬសម្ភារ ងាយយល់ សមស្របនឹងសង្គម ទាក់ទងគ្នា ប្រាកដនិយម និង ទាក់ទាញ។

### ៨.៣. ការពិនិត្យ និងកែសម្រួលសារអប់រំ EORE ឡើងវិញ

សារអប់រំ និងការផ្តល់សារអប់រំ គួរត្រូវបានត្រួតពិនិត្យ ដោយគ្រប់គម្រោង ឬកម្មវិធី EORE ដើម្បីជានាប្រសិទ្ធភាព។ ប្រព័ន្ធត្រួតពិនិត្យ គួរត្រូវបានបង្កើតឡើងក្នុងដំណាក់កាលរៀបចំផែនការ ដើម្បីដឹងថាសារអប់រំៈ

ក) ស្របតាមបរិបទជាក់ស្តែង។

ខ) បានទៅដល់ក្រុមគោលដៅ។

គ) ងាយយល់ និងទទួលយកបាន (ការផ្លាស់ប្តូរចំណេះដឹង និងអាកប្បកិរិយា)។

ឃ) ផ្លាស់ប្តូរឥរិយាបថ។

### ៨.៤. ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ និងសម្ភារ

ការកំណត់នូវតម្រូវការផ្សព្វផ្សាយ និងសម្ភារដើម្បីគាំទ្រ EORE មានការលំបាកជាច្រើនក្នុងការបង្កើតសារអប់រំដែលត្រឹមត្រូវសម្រាប់ក្រុមគោលដៅ ដូចនេះយើងត្រូវពិចារណាទៅលើភាសា និមិត្តសញ្ញា និងសម្ភារផ្សេងៗ។

ប្រព័ន្ធផ្សព្វផ្សាយ និងសម្ភារទាំងនោះ រួមមានៈ វិទ្យុ ទូរទស្សន៍ វីដេអូ បណ្តាញផ្សព្វផ្សាយសង្គម សារជាអក្សរ កម្មវិធីទូរស័ព្ទ ការសម្តែងខ្លីៗ ល្ខោន និងសម្ភារបោះពុម្ពនានា។ មិនគួរយកសម្ភារ EORE ដែលបានបង្កើតឡើងក្នុងបរិបទផ្សេងមកប្រើប្រាស់ទេ ព្រោះអាចបំភាន់ច្រលំ ឬមានភាពមិនសមរម្យក្នុងស្ថានភាពជាក់ស្តែង។ ដូចនេះប្រតិបត្តិករ EORE គួរផ្ញើសម្ភារអប់រំមកអាជ្ញាធរមីន ដើម្បីស្នើសុំធាតុចូល/ការឯកភាពពីសមាជិកនៃក្រុមការងារបច្ចេកទេស TRG-EORE។

ប្រព័ន្ធផ្សព្វផ្សាយ និងសម្ភារ EORE ត្រូវធ្វើការសាកល្បងដូចការបង្កើត និងការផ្តល់សារអប់រំ EORE ដែរ។ ប្រព័ន្ធផ្សព្វផ្សាយ និងសម្ភារគួរត្រូវបានត្រួតពិនិត្យជាប្រចាំ ដែលជាផ្នែកមួយរបស់ប្រព័ន្ធត្រួតពិនិត្យតាមដានកម្មវិធី ឬគម្រោង។

## ៩. ការអនុវត្ត

ជោគជ័យនៃការអនុវត្តគម្រោង ឬកម្មវិធី EORE អាស្រ័យលើការប្រើប្រាស់ឧបករណ៍ សម្ភារ វិធីសាស្ត្រសមស្របតាមផែនការដែលបានគ្រោងទុក និងសមត្ថភាពក្នុងការកែសម្រួលឆ្លើយតបទៅនឹងតម្រូវការដែលមានការប្រែប្រួល និងរបាយការណ៍វឌ្ឍនភាព ព្រមទាំងបទពិសោធន៍ល្អៗ។

### ៩.១. EORE ក្នុងស្ថានភាពបន្ទាន់

EORE ក្នុងស្ថានភាពបន្ទាន់សំដៅទៅលើកិច្ចខិតខំប្រឹងប្រែង ដើម្បីលើកកម្ពស់ការយល់ដឹងអំពីហានិភ័យដែលបណ្តាលមកពីយុទ្ធភណ្ឌគ្រឿងផ្ទុះ ក្នុងគោលបំណងដើម្បីជំរុញឲ្យមានឥរិយាបថ

សុវត្ថិភាពចំពោះ ស្ត្រី កុមារី កុមារា និងបុរសដែលងាយរងគ្រោះ។ ស្ថានភាពបន្ទាន់អាចមានរយៈពេលជាច្រើនថ្ងៃ សប្តាហ៍ ឬខែ។

ក្នុងករណីមានស្ថានភាពបន្ទាន់ ប្រតិបត្តិករ EORE ត្រូវតែពិភាក្សាជាមួយអាជ្ញាធរមីន និងស្ថាប័នពាក់ព័ន្ធ (ឧទាហរណ៍ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងសុខាភិបាលសម្រាប់ជំងឺរាតត្បាត ឬវិបត្តិសុខភាពផ្សេងទៀត) ដើម្បីរៀបចំសារ និងវិធីសាស្ត្រសមស្របនានា ដើម្បីឆ្លើយតបទៅនឹងជនរងគ្រោះដោយ EO។

### ៩.២. ការអនុវត្ត EORE នៅតាមសាលារៀន

នៅប្រទេសកម្ពុជា EORE ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិ តាមរយៈសៀវភៅសិក្សា មានចំណងជើងថា "វិធីបង្ការ និងសង្គ្រោះជនរងគ្រោះថ្នាក់ ឬរបួសផ្សេងៗ" ដែលបានដាក់ឲ្យប្រើប្រាស់ទូទាំងប្រទេសសម្រាប់សិស្សសាលាបឋមសិក្សា និងអនុវិទ្យាល័យចាប់តាំងពីឆ្នាំ២០០៧ ។ លោកគ្រូអ្នកគ្រូគួរតែពិចារណាដូចចំណុចខាងក្រោម៖

ក) បិទផ្ទាំងរូបភាពលើជញ្ជាំងថ្នាក់រៀន ហើយរំលឹកសិស្សជាប្រចាំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។

ខ) សហការជាមួយនគរបាលមូលដ្ឋាន ដើម្បីផ្តល់ការពន្យល់អំពីខ្លឹមសារច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ។

គ) ប្រើកម្មវិធីកុមារទៅកាន់កុមារ ការសម្តែងក្លឹបមិត្តអប់រំមិត្ត ដើម្បីឲ្យសារអប់រំទៅដល់កុមារ ឬយុវវ័យ ដែលមិនមានឱកាសចូលរៀន។

ឃ)ទំនាក់ទំនងជាមួយប្រតិបត្តិករ EORE ដើម្បីធានាបានថាសកម្មភាព EORE អនុវត្តន៍បានពេញលេញ។

## ១០. ការត្រួតពិនិត្យ និងវាយតម្លៃ

ការត្រួតពិនិត្យគឺជាសកម្មភាពបន្តបន្ទាប់ដែលគួរធានាគុណភាព EORE និងលទ្ធផលរយៈពេលខ្លី មធ្យម និងវែងរបស់គម្រោង ឬកម្មវិធី តាមរយៈការអនុវត្តស្របតាមផែនការ។ ការវាយតម្លៃគួរផ្តោតលើសមិទ្ធិផលសម្រេចបាន គោលបំណង ផលរយៈពេលវែង របស់គម្រោង ឬកម្មវិធី EORE គណនេយ្យភាព និងបទពិសោធន៍។

### ១០.១. ការត្រួតពិនិត្យវឌ្ឍនភាពនៃ EORE

ប្រតិបត្តិករ EORE ត្រូវបញ្ជូនរបាយការណ៍ EORE ឲ្យបានទៀងទាត់ និងរបាយការណ៍វឌ្ឍនភាពនៅពេលចាំបាច់មកអាជ្ញាធរមីន ដោយប្រើប្រាស់ទម្រង់របាយការណ៍ ដែលមានលក្ខណៈស្តង់ដាររួម ដែលបង្កើតឡើងរួមគ្នារវាងអាជ្ញាធរមីន និងប្រតិបត្តិករ EORE។

នៅក្នុងប្រទេសកម្ពុជា ប្រតិបត្តិករ EORE ត្រូវតែអនុវត្តការត្រួតពិនិត្យគុណភាពផ្ទៃក្នុង និងពីខាងក្រៅ (QA) ដូចគ្នានឹងសកម្មភាពមីនផ្សេងទៀត ដោយអាជ្ញាធរមីនជាអ្នកត្រួតពិនិត្យគុណភាពចុងក្រោយ។ ការត្រួតពិនិត្យត្រូវបានអនុវត្តដើម្បីវាស់វែងវឌ្ឍនភាពនៃគម្រោង ឬកម្មវិធី EORE។ ការត្រួតពិនិត្យរួមមាន៖

ក) ប្រសិទ្ធភាព និងប្រសិទ្ធផលនៃការផ្តល់សារអប់រំ EORE។

ខ) ការយល់ឃើញអំពីសកម្មភាព EORE របស់សហគមន៍ងាយរងគ្រោះថ្នាក់។

គ) ចំណេះដឹងកើនឡើង និងការចងចាំ។

ឃ) លទ្ធផលនៃការផ្លាស់ប្តូរឥរិយាបថ។

ង) វិសាលភាពភូមិសាស្ត្រ។

ច) គោលការណ៍សមធម៌ (វិសាលភាពដែលជនងាយរងគ្រោះកំពុងត្រូវបានផ្តល់អាទិភាពជូន)។

ឆ) មូលហេតុប្រថុយប្រថាន ឥរិយាបថថ្មីៗ ការសម្របខ្លួនទៅនឹងគ្រោះថ្នាក់។

ជ) ឧប្បត្តិហេតុ និងជនរងគ្រោះថ្នាក់ដោយសារ EO។

ឈ)ការផ្លាស់ប្តូរការគំរាមកំហែង EO ក្រុមហានិភ័យគោលដៅ ការផ្លាស់ប្តូរប្រជាសាស្ត្រ និងវប្បធម៌ដែលជះឥទ្ធិពលដល់អ្នកដែលមានគ្រោះថ្នាក់បំផុត និងបរិបទនយោបាយ និងសង្គមកាន់តែទូលំទូលាយ ដែលអាចជះឥទ្ធិពលដល់សមត្ថភាពរបស់មនុស្សក្នុងការឆ្លើយតបចំពោះ EORE ក្នុងលក្ខណៈសមស្រប។

ញ)សុវត្ថិភាពដល់បុគ្គលិកអនុវត្ត EORE។

ដ) បុគ្គលិកអនុវត្ត EORE ត្រូវមានសមត្ថភាព ប្រសិនបើពួកគេទទួលបានការបណ្តុះបណ្តាលសមស្រប (រាល់ការបណ្តុះបណ្តាលត្រូវកត់ត្រាទុក)។

ឋ) អនុវត្តតាមស្តង់ដារប្រតិបត្តិការរបស់ប្រតិបត្តិករ EORE និងតាមស្តង់ដារ។

ការត្រួតពិនិត្យផ្ទៃក្នុងគួរ៖

ក) ធានាថាសកម្មភាពដែលបានអនុវត្តឆ្លុះបញ្ចាំងពីការប្រែប្រួលនៃតម្រូវការ EORE ឬតាមកាលៈទេសៈ។

ខ) រៀបចំឯកសារពីបទពិសោធន៍ល្អ។

គ) រួមមាន៖

- ការអង្កេតសកម្មភាពបណ្តុះបណ្តាលដល់បុគ្គលិក និងអ្នកស្ម័គ្រចិត្ត។
- ការពិនិត្យផ្ទាល់នៅកន្លែងអនុវត្ត EORE ក្នុងសហគមន៍។
- ការតាមដានសកម្មភាពកំពុងអនុវត្ត EORE។
- ការអង្កេតមើលការចូលរួមរបស់សហគមន៍ក្នុងសកម្មភាព និងវាស់វែងលទ្ធផលនៃការផ្លាស់ប្តូរឥរិយាបថ។

- ការអង្កេតមើលពីការសាកល្បង និងវាយតម្លៃលើសម្ភារ EORE នៅទីវាល។

ការត្រួតពិនិត្យពីស្ថាប័នខាងក្រៅ គួរធ្វើឡើងដោយអាជ្ញាធរមីន តាមរយៈផែនការ និងរបាយការណ៍ការងាររបស់ប្រតិបត្តិករ EORE ឬ ការត្រួតពិនិត្យនៅទីវាលដើម្បីៈ

ក) ពិនិត្យវឌ្ឍនភាព និងសកម្មភាពកែតម្រូវប្រសិនបើមាន ធៀបនឹងរបាយការណ៍ត្រួតពិនិត្យពីមុន។
ខ) ការអនុលោមតាម SOPs របស់ប្រតិបត្តិករ និងស្តង់ដារជាតិសកម្មភាពមីន (CMAS)។
គ) ផ្ទៀងផ្ទាត់នីតិវិធីធានាគុណភាព (QA) របស់ប្រតិបត្តិករ EORE។
ឃ) ផ្តល់មតិយោបល់ដល់ប្រតិបត្តិករអំពីវិធីកែតម្រូវសកម្មភាព។
ង) វាស់វែងចំណេះដឹងអ្នកទទួលបានសារអប់រំ ដើម្បីធានាប្រសិទ្ធភាពនៃការផ្តល់សារអប់រំ EORE។

ការត្រួតពិនិត្យខាងក្រៅមិនអាចជំនួសឲ្យការត្រួតពិនិត្យផ្ទៃក្នុងទេ។ ការត្រួតពិនិត្យគួរតែបង្កើតឲ្យមានសកម្មភាព និងអនុសាសន៍ដែលអាចជួយកែសម្រួលផែនការសកម្មភាព និងធ្វើឲ្យប្រសើរឡើងនូវការអនុវត្តគម្រោង ដើម្បីសម្រេចបានលទ្ធផលរយៈពេលវែង។

### ១០.២. ការបង្កើតប្រព័ន្ធត្រួតពិនិត្យ

ជាអប្បបរមា ប្រព័ន្ធត្រួតពិនិត្យដែលបង្កើតឡើងគួរអាចៈ

ក) កំណត់សូចនាករនៃការវាស់វែងរួមមានៈ ទិន្នន័យពាក់ព័ន្ធការបែងចែកតាមភេទ និងអាយុ ដែលផ្តោតលើ ប្រសិទ្ធភាព ប្រសិទ្ធផល លទ្ធផលរយៈពេលវែង និងនិរន្តរភាព។
ខ) បង្កើតប្រព័ន្ធប្រមូល និងកត់ត្រាព័ត៌មាន ទាក់ទងនឹងសូចនាករទាំងនេះ។
គ) ធានាថាទិន្នន័យដែលប្រមូលបាន អាចវិភាគ និងប្រើប្រាស់។
ឃ) ធានាថាព័ត៌មានត្រូវបានប្រើប្រាស់ដើម្បីជូនដំណឹងដល់ប្រធានគ្រប់គ្រងកម្មវិធី/គម្រោង។
ង) ធានានូវការអនុលោមទៅតាម SOPs របស់ប្រតិបត្តិករ និង CMAS។
ច) ធានាថា EORE ត្រូវបានកែសម្រួលដោយផ្អែកលើព័ត៌មានដែលប្រមូលបានពីការត្រួតពិនិត្យដើម្បីគាំទ្រដល់ការសម្រេចបាននូវគោលដៅ។

### ១០.៣. សកម្មភាពកែតម្រូវ

បញ្ហាដែលបានរកឃើញក្នុងអំឡុងពេលត្រួតពិនិត្យ គួរត្រូវបានដោះស្រាយដោយប្រតិបត្តិករ EORE។

ប្រសិនបើបញ្ហាមានភាពធ្ងន់ធ្ងរប្រតិបត្តិករ EORE គួរបង្ហាញសកម្មភាពកែតម្រូវរបស់ខ្លួនទៅអាជ្ញាធរមីន ដោយអនុលោមតាមតម្រូវការដែលបានចែង។

១០.៤. ការវាយតម្លៃ

ការវាយតម្លៃ បានផ្តល់នូវអនុសាសន៍សំខាន់ៗដែលអាចជួយកែលម្អសកម្មភាព EORE នាពេលអនាគត។ ការវាយតម្លៃអាចធ្វើលើគម្រោង ឬកម្មវិធី ដោយ EORE ជាផ្នែកមួយនៃផែនការការងាររយៈពេលវែង ឬជាផ្នែកមួយនៃ NMAS ។ គោលបំណងនៃការវាយតម្លៃ EORE គឺដើម្បីវាស់វែងលើចំណុចខាងក្រោម៖

ក) **ប្រសិទ្ធភាព** វិសាលភាពដែលគម្រោង ឬកម្មវិធី សម្រេចបានលទ្ធផលរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពទាក់ទងនឹងធាតុចូល។

ខ) **ភាពពាក់ព័ន្ធ ឬភាពសមស្រប** វិសាលភាពដែលគម្រោង ឬកម្មវិធីឆ្លើយតបទៅនឹងតម្រូវការការរំពឹងទុក និងអាទិភាពនានានៃក្រុមអ្នកទទួលផលគោលដៅ និងម្ចាស់ជំនួយ។

គ) **ប្រសិទ្ធផល** វិសាលភាពដែលគម្រោង ឬកម្មវិធីសម្រេចគោលបំណង និងគោលដៅរយៈពេលមធ្យមរបស់ខ្លួន (លទ្ធផល)។

ឃ) **ឥទ្ធិពល** អត្ថប្រយោជន៍រយៈពេលវែងនៃគម្រោង ឬកម្មវិធីដល់អ្នកទទួលផល និងភាគីពាក់ព័ន្ធដទៃទៀតរាប់ទាំងអ្នកទទួលផលផ្ទាល់ ឬដោយប្រយោល ចេតនា ឬអចេតនា។

ង) **និរន្តរភាព** លទ្ធភាពដែលគុណប្រយោជន៍នានាដែលសម្រេចបានដោយគម្រោង ឬកម្មវិធី បន្តមានទោះបីជាធាតុចូលដូចជាមូលនិធិខាងក្រៅ និងជំនួយជាបុគ្គលត្រូវបានបញ្ចប់ទៅហើយក្តី។

អាជ្ញាធរមីន និងប្រតិបត្តិករ EORE គួរមានការវាយតម្លៃដែលជាផ្នែកមួយនៃផែនការប្រតិបត្តិការ និងការអនុវត្តសកម្មភាព។ ការវាយតម្លៃលើគុណភាពនៃសកម្មភាព EORE នឹងជានាឲ្យមាននូវវឌ្ឍនភាពក្នុងការសម្រេចគោលដៅ។ ដើម្បីអនុវត្តការវាយតម្លៃ អាជ្ញាធរមីន និងប្រតិបត្តិករ គួរធានាឲ្យមានចំណុចដូចខាងក្រោម៖

ក) មានភាគីពាក់ព័ន្ធ ចូលរួមក្នុងដំណើរការវាយតម្លៃ។
ខ) អ្នកវាយតម្លៃត្រូវសង្ខេបនិងគាំទ្រ និងមានឥរិយាបថប្រកបដោយវិជ្ជាជីវៈ និងមិនលំអៀង។
គ) លទ្ធផលនៃការវាយតម្លៃគួរតែចែករំលែកជាមួយអាជ្ញាធរមីន និងសមាជិកក្រុមការងារបច្ចេកទេស EORE TRG។
ឃ) លទ្ធផលនៃការវាយតម្លៃត្រូវបានអនុវត្តទៅលើសកម្មភាព EORE នាពេលអនាគត។

ការវាយតម្លៃអាចធ្វើឡើងនៅក្នុងដំណាក់កាលផ្សេងៗគ្នានៃ NMAS តាមផែនការការងារគម្រោង ឬ កម្មវិធីជាច្រើនឆ្នាំ ។ កត្តាដែលគួរពិចារណាមានដូចខាងក្រោម៖

ក) NMAS ផែនការការងារគម្រោងឬកម្មវិធីច្រើនឆ្នាំមានគោលដៅរយៈពេលខ្លី ឬ វែង។

ខ) វិធីសាស្ត្រត្រួតពិនិត្យប្រភេទណាដែលត្រូវបានប្រើប្រាស់រួចហើយ។

គ) តម្រូវការអ្នកវាយតម្លៃពីខាងក្រៅ។

ឃ) អាចមានធនធានសម្រាប់ធ្វើការវាយតម្លៃ។

ង) ផលប៉ះពាល់នៃការវាយតម្លៃផ្នែកទៅលើពេលវេលារបស់ប្រជាពលរដ្ឋ (បុគ្គលិកដែលពាក់ព័ន្ធនិងអ្នកទទួលផលប្រយោជន៍)។

## ១១. ការអភិវឌ្ឍសមត្ថភាព

ការអភិវឌ្ឍសមត្ថភាពគឺជាឆ្អឹងខ្នងក្នុងគ្រប់វិស័យរួមទាំងសកម្មភាពមីន។ ការកែលម្អជាបន្តបន្ទាប់លើសមត្ថភាព គឺជានិច្ចជាកាលជាអាទិភាពមួយហើយនឹងត្រូវធ្វើឲ្យបាន។ ការស្រាវជ្រាវ និងការអភិវឌ្ឍការប្រើប្រាស់វិធីសាស្ត្រ ឧបករណ៍ ជំនាញ ការចងក្រងបទពិសោធន៍ សុទ្ធសឹងតែមានសារៈសំខាន់ក្នុង EORE។ ការអភិវឌ្ឍសមត្ថភាពត្រូវបានសង្កត់ធ្ងន់នៅក្នុងអនុសញ្ញាមនុស្សធម៌នានារួមទាំងសកម្មភាពទី៣១ នៃផែនការសកម្មភាពអូស្លូ។

### ១១.១. បង្កើតផែនការអភិវឌ្ឍសមត្ថភាព

ផែនការអភិវឌ្ឍសមត្ថភាពគួរតែមានធាតុដូចខាងក្រោម:

ក) ចក្ខុវិស័យរបស់ភាគីពាក់ព័ន្ធនិងការយល់ដឹងអំពីគម្លាតបច្ចុប្បន្ននៃសមត្ថភាពគ្រប់គ្រង។

ខ) សកម្មភាពសំរាប់ដោះស្រាយបញ្ហានីមួយៗដោយចងចាំនូវចក្ខុវិស័យរួម។

គ) គោលការណ៍ និងលទ្ធផលជាក់លាក់ដែលត្រូវសំរេចបានទៅតាមគោលដៅដែលបានចែងនីមួយៗ។

ឃ) ដំណើរការដើម្បីសម្រេចគោលបំណងនីមួយៗ។

ង) ការបែងចែកយ៉ាងច្បាស់ថាតើអ្នកណាទទួលខុសត្រូវចំពោះការគាំទ្រ ការអនុវត្ត ឬការដាក់ផែនការឲ្យអនុវត្ត។

ច) ការបង្កើតថ្មីដើម្បីបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលនៃ EORE។

### ១១.២. សហគមន៍ដែលមានហានិភ័យ

កិច្ចខិតខំប្រឹងប្រែងដើម្បីពង្រឹងសមត្ថភាពសហគមន៍ សម្រាប់ការងារអប់រំគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ គួរតែជាផ្នែកដ៏សំខាន់មួយនៃ EORE ដោយរួមមានការបង្កើតបណ្តាញអ្នកស្ម័គ្រចិត្ត និងពង្រឹងកិច្ចខិតខំប្រឹងប្រែងគ្រប់គ្រងហានិភ័យនៅសហគមន៍។ ការអភិវឌ្ឍសមត្ថភាពអាចគ្របដណ្តប់លើផ្នែកគ្រប់គ្រងព័ត៌មាន គ្រប់គ្រងហានិភ័យ និងផ្តល់សារអប់រំ EORE។ ការគ្រប់គ្រងហានិភ័យនៅក្នុងបរិបទនេះ សំដៅលើគំនិតផ្តួចផ្តើមដូចជាការដាក់ស្លាកសញ្ញា ឬការហ៊ុមព័ទ្ធលើតំបន់មានហានិភ័យ ស្វែងយល់អំពីជម្រើសក្នុងការប្រថុយប្រថាន និងការប្រើប្រាស់វិធីសាស្ត្រផ្សេងៗដើម្បី

ទទួលបានធនធាននិងជីវិតរស់នៅដោយពុំចាំបាច់មានការបោសសម្អាតមីន/គ្រាប់រួច ឬចូលទៅកាន់តំបន់គ្រោះថ្នាក់នានា។

### ១១.៣. អាជ្ញាធរមីន

អាជ្ញាធរមីនគួរមានលទ្ធភាពក្នុងការដាក់ចេញជាយុទ្ធសាស្ត្រការងារ EORE ដើម្បីចូលរួមចំណែកលើការកាត់បន្ថយគ្រោះថ្នាក់ និងប្រសិទ្ធភាពសកម្មភាពមីន។ អាណត្តិអាជ្ញាធរមីនក្នុងការសម្របសម្រួល ត្រួតពិនិត្យ និងដឹកនាំការងារ EORE ឲ្យកាន់តែប្រសើរឡើងតាមរយៈការគ្រប់គ្រងព័ត៌មាន ការគ្រប់គ្រងគុណភាព ការវាស់វែងតម្រូវការ ការកសាងផែនការ ការត្រួតពិនិត្យ និងការវាយតម្លៃ គឺចាំបាច់ដើម្បីទទួលបានជោគជ័យលើការងារ EORE ។

### ១១.៤. ប្រតិបត្តិករ EORE

ប្រតិបត្តិករEORE គួរមានសមត្ថភាពវាស់វែង កសាងផែនការ បណ្តុះបណ្តាល អនុវត្ត តាមដាន និងវាយតម្លៃការងារ EORE ។ ការប្រើប្រាស់វិធីសាស្ត្រ និងបច្ចេកទេស PRA គឺជាកិច្ចការគ្រប់គ្រងដ៏ស្មុគស្មាញមួយដែលទាមទារជំនាញ និងចំណេះដឹងដើម្បីសម្រេចវាបាន ដែលដូចគ្នាជាមួយនឹងតម្រូវការក្នុងការរាយការណ៍អំពីការអនុវត្តការងារEORE មកកាន់អាជ្ញាធរមីនដោយប្រើប្រាស់ទម្រង់របាយការណ៍ជាស្តង់ដាររួម និងឲ្យទាន់ពេលវេលា ។ ការធ្វើរបាយការណ៍ប្រកបដោយប្រសិទ្ធភាពនឹងនាំមកនូវការគ្រប់គ្រងព័ត៌មានប្រកបដោយប្រសិទ្ធភាព ដែលផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនដូចមានចែងនៅក្នុងបទដ្ឋាននេះ។

## ១២. ប័ណ្ណទទួលស្គាល់ស្ថាប័ន និងអាជ្ញាប័ណ្ណប្រតិបត្តិការ

ប្រតិបត្តិករ EORE ត្រូវមានប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណប្រតិបត្តិការចេញដោយអាជ្ញាធរមីនស្របតាមស្តង់ដារជំពូក ០២៖ ស្តីពីប័ណ្ណទទួលស្គាល់ស្ថាប័ន និងអាជ្ញាប័ណ្ណប្រតិបត្តិការ សម្រាប់អនុវត្តវិស័យសកម្មភាពមីន។

## ១៣. តួនាទី និងការទទួលខុសត្រូវ

### ១៣.១. អាជ្ញាធរមីន

អាជ្ញាធរមីនគួរតែ៖

ក) ធានាថា សកម្មភាព EORE ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសកម្មភាពមីន។

ខ) បង្កើត និងនៅពេលចាំបាច់កែប្រែ CMAS ទម្រង់ស្តង់ដារ និងគោលការណ៍ណែនាំស្តីពី EORE។

គ) ផ្តល់ និងបន្តប័ណ្ណទទួលស្គាល់ស្ថាប័ន និងអាជ្ញាប័ណ្ណប្រតិបត្តិការរបស់ប្រតិបត្តិករ EORE។

ឃ)ធានាថារាល់សកម្មភាព EORE អនុវត្តស្របតាម NMAS ផែនការការងាររយៈពេលវែង និងស្តង់ដារ EORE។

ង) សម្របសម្រួល និងត្រួតពិនិត្យការអនុវត្តរបស់ប្រតិបត្តិករ EORE ។

ច) សហការជាមួយស្ថាប័នពាក់ព័ន្ធដទៃទៀតដើម្បីអនុវត្ត EORE ។

ឆ) កៀរគរធនធានដើម្បីអនុវត្ត EORE រួមមានធ្វើការទំនាក់ទំនងជាមួយម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍។

ជ) អភិវឌ្ឍន៍សមត្ថភាពជាតិ EORE ប្រកបដោយចីរភាព។

ឈ) សម្របសម្រួលការអនុវត្តការវាយតម្លៃតម្រូវការ EORE ។

ញ) បង្កើតបញ្ជីភូមិអាទិភាពដោយពិគ្រោះយោបល់ជាមួយប្រតិបត្តិករ EORE។

ដ) គ្រប់គ្រងទិន្នន័យជាតិសម្រាប់ EORE និងធានាថាទិន្នន័យមាន សម្រាប់តម្រូវការសម្ងាត់របស់ប្រតិបត្តិករ EORE និងភាគីពាក់ព័ន្ធ។

ឋ) រៀបចំការវាយតម្លៃពីខាងក្រៅសម្រាប់សកម្មភាព EORE ទាំងមូល។

## ១៣.២. ប្រតិបត្តិករ EORE

ប្រតិបត្តិករ EORE ត្រូវតែះ

ក) ទទួលប័ណ្ណទទួលស្គាល់ស្ថាប័ន និងអាជ្ញាប័ណ្ណប្រតិបត្តិការពីអាជ្ញាធរមីន។

ខ) ទទួលការយល់ព្រមពីអាជ្ញាធរមីនលើផែនការសកម្មភាពការងារ។

គ) អនុវត្តសកម្មភាព EORE ស្របតាម NMAS ផែនការការងាររយៈពេលវែង និងស្តង់ដារ EORE ។

ឃ)ធានាថាបុគ្គលិកទាំងអស់ដែលអនុវត្តសកម្មភាព EORE មានសមត្ថភាព និងទទួលបានការបណ្តុះបណ្តាល បំពាក់ឧបករណ៍ និងមានគុណសម្បត្តិ។

ង) រក្សាកំណត់ត្រាគ្រប់សកម្មភាពទាំងអស់ឲ្យបានត្រឹមត្រូវ និងផ្តល់ឲ្យអាជ្ញាធរមីននូវរបាយការណ៍ទៀងទាត់តាមទម្រង់របាយការណ៍ស្តង់ដារ និងទិន្នន័យចាំបាច់ដទៃទៀតដែលពាក់ព័ន្ធនឹងការអនុវត្ត EORE ។

ច) បង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

# កំណត់ត្រាការកែសម្រួល

## ការគ្រប់គ្រងការកែសម្រួលស្តង់ដារអប់រំគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ស្តង់ដារនេះ តម្រូវឲ្យមានការកែសម្រួលជារៀងរាល់បីឆ្នាំ។ ទោះជាយ៉ាងនេះក្តី ស្តង់ដារនេះមិនរារាំងការកែសម្រួលដែលត្រូវបានធ្វើឡើងក្នុងពេលណាមួយនៃរយៈកាលបីឆ្នាំនេះទេ បើសិនមានមូលហេតុសមរម្យដូចជា សុវត្ថិភាពនិងប្រសិទ្ធភាពនៃប្រតិបត្តិការ ឬសម្រាប់គោលបំណងវិចារណកថា។ នៅពេលណាមានការកែប្រែលើស្តង់ដារនេះត្រូវមានការកត់ត្រានូវលេខយោង កាលបរិច្ឆេទ និងសេចក្តីលម្អិតនៃការកែប្រែទាំងនោះ ដាក់ក្នុងតារាងខាងក្រោម។

នៅពេលណាមានការកែសម្រួលស្តង់ដារនេះជាផ្លូវការ ខ្លឹមសារកែប្រែថ្មីនឹងត្រូវបានរៀបចំឡើង។ បច្ចុប្បន្នភាពនៃការកែសម្រួលត្រូវកត់ត្រាបញ្ចូលទៅក្នុងតារាងខាងក្រោម ។ បច្ចុប្បន្នភាពនៃការកែសម្រួលនឹងត្រូវបានកត់ត្រាម្តងទៀត នៅពេលណាមានការកែសម្រួលលើកក្រោយៗ ។

| ល.រ | ថ្ងៃខែឆ្នាំ | លម្អិតការកែសម្រួល |
|---|---|---|
| 1 | …. | ១. ចំណងជើងត្រូវបានធ្វើបច្ចុប្បន្នភាព" ការអប់រំអំពីយុទ្ធភណ្ឌគ្រឿងផ្ទុះ (ជាថ្មី)"<br>២. ពាក្យ" EORE" ជំនួស" MRE" នៅក្នុងឯកសារទាំងមូល<br>៣. ផ្នែកពាក់ព័ន្ធនឹងយេនឌ័រត្រូវបានធ្វើបច្ចុប្បន្នភាព" ស្ត្រី កុមារី កុមារា និងបុរស" នៅក្នុងឯកសារទាំងមូល<br>៤. ការកែសម្រួលលើអក្ខរាវិរុទ្ធ និងបន្តិចបន្តួចផ្សេងទៀតនៅទូទាំងឯកសារ<br>៥. កថាខណ្ឌ" ១. ការទទួលស្គាល់" ត្រូវបានដកចេញដើម្បីឲ្យស្របទៅនឹង CMAS ផ្សេងទៀត និងដាក់លេខកថាខណ្ឌទាំងអស់ឡើងវិញ<br>៦. កថាខណ្ឌ" សេចក្តីផ្តើម" ត្រូវបានធ្វើបច្ចុប្បន្នភាព<br>៧." ២. គោលបំណងនៃឯកសារនេះ" ជំនួសដោយ" ១. វិសាលភាព"<br>៨. កថាខណ្ឌ" ៣. លក្ខខណ្ឌ និយមន័យ និងអក្សរកាត់" បានធ្វើបច្ចុប្បន្នភាពទៅជា" ២. លក្ខខណ្ឌ និងនិយមន័យ"<br>៩. កថាខណ្ឌ ២៖ បន្ថែមលក្ខខណ្ឌដូចតទៅ" យុទ្ធភណ្ឌគ្រឿងផ្ទុះ (EO) ការអប់រំអំពីយុទ្ធភណ្ឌគ្រឿងផ្ទុះ (EORE) ប្រតិបត្តិករ EORE ក្រុមការងារ EORE គម្រោង និងកម្មវិធី" និងបានធ្វើបច្ចុប្បន្នភាពលើលក្ខខ័ណ្ឌទាំងនេះ។ |

| | | |
|---|---|---|
| | | ១០. កថាខណ្ឌ"៤. គោលការណ៍មនុស្សធម៌" ត្រូវបានដកចេញ។<br>១១. កថាខណ្ឌ" ៣ EORE ទូទៅ" បន្ថែមលើការឆ្លុះបញ្ចាំងអំពី IMAS<br>១២.១០. ផែនការសកម្មភាពអូស្លូ និងគោលការណ៍មនុស្សធម៌<br>១២. កថាខណ្ឌ"ធាតុផ្សំនៃការអប់រំយល់ដឹងពីមីន "បានធ្វើបច្ចុប្បន្នភាពជា" ៣.២. សមាសធាតុសំខាន់ៗនៃ EORE" និងតួសេចក្តីត្រូវបានធ្វើបច្ចុប្បន្នភាព។<br>១៣. កថាខណ្ឌ ៦.ការទទួលខុសត្រូវទូទៅរបស់ប្រតិបត្តិករ MRE។ ចំណងជើង និងតួសេចក្តី និងប្តូរទៅ កថាខណ្ឌ "១៣ តួនាទី និងការទទួលខុសត្រូវ"។<br>១៤.កថាខណ្ឌ " ៧. តួនាទីរបស់ MRE ក្នុងសកម្មភាពមីន" បានធ្វើបច្ចុប្បន្នភាពជា" ៤. តួនាទីរបស់ EORE ក្នុងសកម្មភាពមីន" និងតួសេចក្តីត្រូវបានធ្វើបច្ចុប្បន្នភាព។<br>១៥. កថាខណ្ឌ "៤.៧. ការអង្កេតរងរបួសដោយសារ EO" បានធ្វើបច្ចុប្បន្នភាពដើម្បីឆ្លុះបញ្ចាំង IMAS ១២.១០ ។<br>១៦. កថាខណ្ឌ " ៨. ការអនុវត្តគោលការណ៍ណែនាំ MRE " បានធ្វើបច្ចុប្បន្នភាពជា" ៥. គោលការណ៍ណែនាំ EORE និងតួសេចក្តីត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីឆ្លុះបញ្ចាំងពីការកែសម្រួល MRE នៅកម្ពុជាឆ្នាំ២០១៣-២០១៩ របស់អង្គការយូនីសេហ្វ និងអាជ្ញាធរមីនឆ្នាំ២០២០ ដោយលោកបណ្ឌិត រ៉ូប៊ឺតខេលលី ( Robert Keeley ) និង វិធីសាស្ត្ររួមក្នុងការអនុវត្ត EORE ក្នុងរដ្ឋភាគីសមាជិកអាស៊ានឆ្នាំ ២០២០ របស់ ARMAC ដោយលោក Hal Judge។<br>១៧. កថាខណ្ឌ ៩. ការអនុម័តលើគម្រោង MRE" បានធ្វើបច្ចុប្បន្នភាពនិងផ្លាស់ប្តូរទៅ" ១២. ការអនុម័តគម្រោង EORE ឬផែនការកម្មវិធី" និងតួសេចក្តីត្រូវបានធ្វើបច្ចុប្បន្នភាព ដើម្បីបញ្ចូលការផ្តល់ការទទួលស្គាល់ដល់ប្រតិបត្តិករ EORE ។<br>១៨. កថាខណ្ឌ " ១០. ការផ្តល់ប័ណ្ណទទួលស្គាល់ប្រតិបត្តិករ MRE " ត្រូវបានដកចេញ<br>១៩. កថាខណ្ឌ ១១. វដ្តគម្រោង MRE" ត្រូវបានដកចេញ ហើយកថាខណ្ឌរងភាគច្រើនក្លាយជាកថាខណ្ឌចម្បង |

| | | |
|---|---|---|
| | | ២០. កថាខណ្ឌ " ១១.១. ការប្រមូលទិន្នន័យ និងការវាយតម្លៃតម្រូវការ" បានធ្វើបច្ចុប្បន្នភាពជា" ៦. ការប្រមូលទិន្នន័យ និងការវាយតម្លៃតម្រូវការ" និងតួសេចក្តីត្រូវបានធ្វើបច្ចុប្បន្នភាព។<br>២១. កថាខណ្ឌ " ១១.២. ការធ្វើផែនការ" បានធ្វើបច្ចុប្បន្នភាពជា" ៧. ការរៀបចំផែនការ" និងត្រូវបានធ្វើបច្ចុប្បន្នភាព។<br>២២. កថាខណ្ឌ "១១.៣.១. ការបញ្ជូនសារអប់រំ និងការផ្តល់សារអប់រំ MRE" ត្រូវបានធ្វើបច្ចុប្បន្នភាពជា" ៨. ការបញ្ជូនសារអប់រំ និងការបញ្ជូនសារអប់រំ EORE និងតួសេចក្តីត្រូវបានធ្វើបច្ចុប្បន្នភាព។<br>២៣. កថាខណ្ឌ "១១.៣. ការអនុវត្ត" បានធ្វើបច្ចុប្បន្នភាពជា "៩. ការអនុវត្ត" និងតួសេចក្តីត្រូវបានធ្វើបច្ចុប្បន្នភាព។<br>២៤. កថាខណ្ឌ "១១.៤. ការត្រួតពិនិត្យ" បានធ្វើបច្ចុប្បន្នភាពជា "១០. ការត្រួតពិនិត្យ និងវាយតម្លៃ" ។<br>២៥. កថាខណ្ឌ "១០.២. ការបង្កើតប្រព័ន្ធត្រួតពិនិត្យ" ត្រូវបានបន្ថែម ។<br>២៦. កថាខណ្ឌ "១២. ការគ្រប់គ្រងគុណភាពសម្រាប់ប្រតិបត្តិការរបស់ MRE " ត្រូវបានដកចេញ និងខ្លឹមសារសំខាន់ៗបញ្ចូលនៅក្នុង "១០. ការត្រួតពិនិត្យ និងវាយតម្លៃ"។<br>២៧. កថាខណ្ឌ "១២.៣ និរន្តរភាពនៃ MRE" បានធ្វើបច្ចុប្បន្នភាពនិងផ្លាស់ប្តូរទៅ "៥.៨ និរន្តរភាពនៃ EORE" ។<br>២៨. កថាខណ្ឌ "១១. ការអភិវឌ្ឍសមត្ថភាព" ត្រូវបានបន្ថែម ដើម្បីឆ្លុះបញ្ចាំង IMAS ១២.១០ ។ |

ឧបសម្ព័ន្ធ ក/**Annex: A**

អាជ្ញាធរមីន
C.M.A.A

# ការអប់រំគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

## Explosive Ordnance Risk Education

# កិច្ចតែងការបង្រៀន

## Lesson Plan

| |
|---|
| កាលបរិច្ឆេទត្រួតពិនិត្យ/Date: |
| លេខក្រុម/Team ID: |
| ការិយាល័យ/Office: |
| ប្រតិបត្តិករ/Operator: |
| ម្ចាស់ជំនួយ/Donor: |

- អាស័យដ្ឋានផ្តល់សារអប់រំ/ Address of EORE session……………………………………………
- ស្ថាប័នផ្តល់សារអប់រំ/Name of organization…………………………………………………………
- រយះពេល/ Duration……………………… ( មិនលើសពី២ម៉ោង/ not to exceed two hours )
- គោលបំណង: អ្នកចូលរួមទទួលបាននូវចំណេះដឹងអំពីផលវិបាកនៃគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ និងឈប់ ឬចៀសវាងប្រព្រឹត្តនូវទង្វើដែលឈានទៅរកគ្រោះថ្នាក់ កត់សម្គាល់គ្រាប់មីន របៀបរាយការណ៍ ស្គាល់ស្លាកសញ្ញាគ្រោះថ្នាក់នៃយុទ្ធភណ្ឌគ្រឿងផ្ទុះ( ផ្លូវការ ក្រៅផ្លូវការ )

  Objective: Participants are aware of the dangers of EO … stop or avoid risky activity… recognize EO… report… recognize EO markings ( formal and informal )
- សម្ភារ:ឧបទ្ទេសអាចមាន: *ផ្ទាំងរូបភាព យុទ្ធភណ្ឌគ្រឿងផ្ទុះសិប្បនិមិត្ត ផែនទី ឯកសារច្បាប់ ស្លាកសញ្ញាមីនគ្រាប់.......................*

  Teaching materials may consist: posters, fake mine/ ERW prop, maps, laws, EO markings
- វិធីសាស្ត្រ /Method………………………

| មាតិកា/ ខ្លឹមសារ<br>Content | សកម្មភាពអ្នកផ្តល់សារអប់រំ<br>Instructor's activities | សកម្មភាពអ្នកទទួលសារអប់រំ<br>Participants' activities |
|---|---|---|
| ១. សេចក្តីផ្តើម ( ៥នាទី )<br>1. Introduction ( 5mn )<br>• ការណែនាំក្រុម ឈ្មោះ និងតួនាទី ស្ថាប័ន គោលបំណង<br>• Self-introduction, team, title, organization, purpose…… | • ណែនាំផ្ទាល់មាត់<br>• Verbal presentation | -ស្តាប់<br>-Listen |
| ២. សេចក្តីបរិយាយស្ថានភាពយុទ្ធភណ្ឌគ្រឿងផ្ទុះ (រយៈពេល)<br>2. Description of EO situation ( Duration… )<br>• ប្រវត្តិសង្គ្រាម/ការដាក់យុទ្ធភណ្ឌគ្រឿងផ្ទុះ<br>History of armed conflicts and EO contamination.<br>• ស្ថានភាពភូមិសាស្ត្រ<br>• Geographic situation. | • បង្ហាញរូបភាព ផែនទី បញ្ចាំងរូបភាពភូមិសាស្ត្រទូទៅ នៅក្នុងសហគមន៍ផ្ទាល់ តំបន់គ្រោះថ្នាក់ ......<br>• Showing pictures, maps, in general in the community, the EO contaminated area......<br>• សួរអំពីតំបន់សង្ស័យ/តំបន់គ្រោះថ្នាក់ក្នុងសហគមន៍ផ្ទាល់<br>• Eliciting answers about suspected areas / dangerous areas in the community. | • ស្តាប់ ពិភាក្សា និង ផ្តល់ចំលើយអំពីតំបន់សុវត្ថិភាព និងតំបន់គ្រោះថ្នាក់ ក្នុងសហគមន៍<br>• Listening, discussing and providing answers about safe and dangerous areas in the community. |
| ៣. បញ្ហា និងផលវិបាកនៃគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ( រយៈពេល........... )<br>3. Negative impacts of EO Accident ( Duration: .... )<br>• ផលវិបាកផ្លូវកាយ ផលវិបាកផ្លូវចិត្ត ផលវិបាកផ្នែកសេដ្ឋកិច្ចសង្គម<br>• Physical consequence, psychological consequence, | • ពន្យល់ផ្ទាល់មាត់ អមដោយការបង្ហាញរូបភាព វីដេអូ........<br>• Oral explanation followed by pictures, video ........<br>• លើកយកស្ថានភាពពិតមកពន្យល់ ( បើមានជនពិការចូលរួម )<br>• Raising real situation of mine victims ( if there are people with disability attending the session ) | • ស្តាប់ការពន្យល់<br>• ចូលរួមផ្តល់ចម្លើយ អំពីបទពិសោធន៍គ្រោះថ្នាក់ ( ធ្លាប់ជួបប្រទះ ឃើញ... )<br>• Listening to the instructor.<br>• Providing answers about risky behaviour ( have seen ... ) |

| | | |
|---|---|---|
| socio-economic consequence.<br>• បង្កគ្រោះថ្នាក់ដល់ មនុស្ស សត្វ ទ្រព្យសម្បត្តិ បរិស្ថាន<br>• Harm to people, animals, property, environment. | | |
| ៤. អត្តសញ្ញាណនៃយុទ្ធភណ្ឌគ្រឿងផ្ទុះ ( រយៈពេល............ )<br>4. EO identification ( Duration: ............ )<br>• ទីតាំង ( ក្រោមដី លើដី ក្នុងព្រៃគម្ពោធ ក្រោមទឹក... ) ទំហំ ប្រភេទ ពណ៌ ឥទ្ធិពល<br>• Location ( underground, on the ground, in the bush, underwater ... ) size, type, colour, impact | • ពន្យល់អំពីប្រភេទ និងឥទ្ធិពលនៃយុទ្ធភណ្ឌគ្រឿងផ្ទុះ អមដោយការបង្ហាញផ្ទាំងរូបភាពរូបសិប្បនិមិត្ត ឬវីដេអូ<br>• Explaining the types and impacts of EO followed by posters, fake EO prop or videos ......... | • ស្តាប់ការពន្យល់<br>• Listening to the instructor |
| ៥. ស្លាកសញ្ញាសម្គាល់យុទ្ធភណ្ឌគ្រឿងផ្ទុះ( រយៈពេល............... )<br>5. EO markings ( Duration: .................... )<br>• ស្លាកសញ្ញាផ្លូវការ<br>• Formal EO markings<br>• ស្លាកសញ្ញាក្រៅផ្លូវការ ( ឈើខ្វែង គួចស្មៅ... )<br>• Informal EO markings ( cross wood, whirl grass ... ) | • ពន្យល់អមដោយមានការបង្ហាញរូបភាព ( ស្លាកសញ្ញាផ្លូវការ និងក្រៅផ្លូវការ )<br>• Oral explanation followed by picture of EO markings ( formal and informal markings ) | • ស្តាប់ការពន្យល់<br>• Listening to the instructor |
| ៦. ឥរិយាបថគ្រោះថ្នាក់( រយៈពេល............ )<br>6. Unsafe/dangerous Behavior ( Duration: ............ )<br>• ការទន្ទ្រានប្រើប្រាស់ដីតំបន់សង្ស័យ | • ពន្យល់អមដោយការបង្ហាញរូបភាព វីដេអូ ឧទាហរណ៍.....<br>• Oral explaining followed by pictures, video or example ........<br>• ស្ថានភាពគ្រោះថ្នាក់ និងសកម្មភាពប្រឈមគ្រោះថ្នាក់ ដែលប្រជាពលរដ្ឋ | • ស្តាប់ការពន្យល់<br>• ចូលរួមផ្តល់ចំលើយអំពីសកម្មភាពប្រឈមគ្រោះថ្នាក់របស់ប្រជាពលរដ្ឋនៅក្នុងតំបន់<br>• Listening to instructor |

| | | |
|---|---|---|
| Invasion of suspected hazardous areas<br>• ប៉ះពាល់ លេង កែច្នៃ ដំ យុទ្ធភណ្ឌគ្រឿងផ្ទុះ<br>• Touch, play, tamper, hit a EO<br>• ជួញដូរយុទ្ធភណ្ឌគ្រឿងផ្ទុះ (លក់/ទិញ ដែកអេតចាយ)<br>• EO trading selling / buying scrap metal)<br>• ការដោះមីនដោយខ្លួនឯង<br>• Informal demining<br>• ការផ្លាស់ទីនៃយុទ្ធភណ្ឌគ្រឿងផ្ទុះ ពីកន្លែងមួយ ទៅកន្លែងមួយ<br>• Movement of EO from one place to another<br>• មិនគោរពស្លាកសញ្ញា យកវាចេញ ឬបង្វិលវា<br>• Disrespect the mine marking, remove or rotate it. | អនុវត្ត ក្នុងសហគមន៍នេះផ្ទាល់ ( ចូលព្រៃរកអនុផលព្រៃឈើ ភ្ជួរដី ច្នៃគ្រាប់ .........)<br>• Dangerous situation and risky activities of people in this community (go into the forest for foraging, land plowing, tampering EO .........) | • providing answers about the risky activities of local people. |
| ៧. ឥរិយាបថសុវត្ថិភាព ( រយៈពេល ............)<br>7. Safe behavior (duration............)<br>• សារ < ឈប់ គិត ជ្រើសរើស ធ្វើសកម្មភាព> នៅតែមានប្រសិទ្ធិភាព<br>• Key messages <Stop, Think, Choose and Act> Remains Effective<br>• សាកសួរព័ត៌មានអំពីតំបន់សុវត្ថិភាព/តំបន់គ្រោះថ្នាក់<br>• Inquire about safe / dangerous zones | • ពន្យល់អមដោយការបង្ហាញរូបភាព វីដេអូ ពន្យល់សកម្មភាព ឬទង្វើចៀសវាងគ្រោះថ្នាក់ ឧទាហរណ៍......<br>• Oral explanation followed by pictures of safe behaviour.<br>• ស្ថានភាពគ្រោះថ្នាក់ និងសកម្មភាពប្រឈមគ្រោះថ្នាក់ ស្ថានភាពជាក់ស្តែងដែលប្រជាពលរដ្ឋអនុវត្ត ក្នុងសហគមន៍នេះផ្ទាល់ ( ចូលព្រៃរកអនុផលព្រៃឈើ ភ្ជួរដី ច្នៃគ្រាប់.........)<br>• Dangerous situation and current risky activities of people in this community (enter the forest, pick vegetables, plowing .........) | • ស្តាប់ការពន្យល់ ពិភាក្សា និងចូលរួមផ្តល់ចំលើយអំពីសកម្មភាពសុវត្ថិភាព។<br>• Report to the team in case a EO found.<br>• រាយការណ៍ជូនក្រុមការងារ ក្នុងករណីបានជួបប្រទះយុទ្ធភណ្ឌគ្រឿងផ្ទុះ។<br>• Listening to the instructor, discussing and providing answers about safety activities. |

| | | |
|---|---|---|
| • ប្រើប្រាស់ផ្លូវដែលគេប្រើជាប្រចាំ និង ចៀសវាងដើរផ្លូវកាត់<br>• Use daily used roads and avoid shortcuts<br>• កុំស៊ីឈ្នួលភ្ជួរត្រាក់ទ័រឲ្យគេបើគ្មានព័ត៌មានច្បាស់លាស់<br>• Do not use plowing machine in EO suspected areas.<br>• កុំប៉ះពាល់ ឬកែច្នៃយុទ្ធភណ្ឌគ្រឿងផ្ទុះ<br>• Do not touch or handle EO.<br>• នៅឲ្យឆ្ងាយពីអ្នកច្នៃយុទ្ធភណ្ឌគ្រឿងផ្ទុះ<br>• Stay away from EO handler | • សួរអ្នកចូលរួម ថាតើពួកគាត់បានជួបប្រទះយុទ្ធភណ្ឌគ្រឿងផ្ទុះឬទេ ?<br>• Asking participants if they have found a EO. | |
| ៨. បញ្ចប់វគ្គ (រយៈពេល.........)<br>8. Conclusion (Duration…)<br>• ត្រួតពិនិត្យចំណេះដឹងអ្នកចូលរួម<br>• Assess participants' understanding. | • សំណួរត្រួតពិនិត្យចំណេះដឹង លើកទឹកចិត្ត (រង្វាន់លើកទឹកចិត្ត........)<br>• Asking questions to assess understanding (Rewards ....)<br>• ផ្តល់ទម្រង់សំនួរចំលើយវាស់ស្ទង់ចំណេះដឹងក្រោយបញ្ចប់វគ្គផ្ដាំផ្ញើ..... អរគុណ...............។<br>• Post-test to measure knowledge after the course. | • ចូលរួមឆ្លើយសំនួរ<br>• Providing answers<br><br>• ចូលរួមបំពេញទម្រង់វាស់ស្ទង់ចំណេះដឹង<br>• Participating in post-test. |

ឧបសម្ព័ន្ធ ខ/**Annex: B**

# ទម្រង់ត្រួតពិនិត្យគុណភាពការអប់រំគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

## Explosive Ordnance Risk Education Quality Assurance Form

អាជ្ញាធរមីន
C.M.A.A

| |
|---|
| លេខកូដត្រួតពិនិត្យ/ QA Code: EORE/QA/CMAA/ |
| កាលបរិច្ឆេទត្រួតពិនិត្យ/Date of QA: |
| លេខក្រុម/Team ID: |
| ការិយាល័យ/Office: |
| ប្រតិបត្តិករ/Operator: |
| ម្ចាស់ជំនួយ/Donor: |

| ទីតាំងធ្វើការត្រួតពិនិត្យ | |
|---|---|
| លេខកូដភូមិ/Village code: | |
| ភូមិ/Village: ☐ ថ្មី/New | ស្រុក/District: ☐ ថ្មី/New |
| ឃុំ/Commune: ☐ ថ្មី/New | ខេត្ត/Province: ☐ ថ្មី/New |
| ចំណុចនិយាមការ/GR: អាប់ស៊ីស/X: | អរដោណេ/Y: |

1. សកម្មភាពអប់រំ/EORE ACTIVITY

1.1.តើបានធ្វើការសម្របសម្រួលជាមួយមូលដ្ឋានដែរឬទេ? ☐ មាន/Yes ☐ មិនមាន/No

Did you liaise with the local authority?

1.2.តើមានការអប់រំចំពោះជនគោលដៅដែរឬទេ? ☐ មាន/Yes ☐ មិនមាន/No

Did you provide EORE to the target people?

1.3.តើមានការអប់រំតាមខ្នងផ្ទះដែរឬទេ? ☐ មាន/Yes ☐ មិនមាន/No

Did you provide EORE by house to house?

1.4.តើមានការអប់រំលក្ខណៈប្រមូលផ្តុំដែរឬទេ? ☐ មាន/Yes ☐ មិនមាន/No

Did you provide EORE to the gathered group of people?

1.5. តើមានការអប់រំតាមសាលារៀនដែរឬទេ? ☐ មាន/Yes ☐ មិនមាន/No

Did you provide EORE at school?

1.6. តើមានការបញ្ជ្រាបសារអប់រំមីនតាមរយៈវេទិកាសាធារណៈដែរឬទេ? ☐ មាន/Yes ☐ មិនមាន/No

Did you provide mainstreamed EORE messages through public forums?

1.7. តើមានការឆ្លើយតបបន្ទាន់អំឡុងពេលអប់រំដែរឬទេ? ☐ មាន/Yes ☐ មិនមាន/No

Did you provide any emergency response during EORE session?

មតិយោបល់/Remarks:

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

**2. អ្នកចូលរួម និងរយៈពេលធ្វើសកម្មភាព/PARTICIPANT AND DURATION OF ACTIVITY**

**2.1. ចំនួនអ្នកចូលរួមសរុប/Total of participant:** ________________________________________

2.1.1 បុរស/Men: ____________________; 2.1.2. ស្ត្រី/Women: ___________________

2.1.3. កុមារអាយុក្រោម ១៨ឆ្នាំ/Boy age<18: ________________________________________

2.1.4. កុមារីអាយុក្រោម ១៨ឆ្នាំ/Girl age<18: ________________________________________

2.1.5. ជនពិការ/Person with disability: បុរស/Man: _______, ស្ត្រី/Woman: _______,

ក្មេង/Children: _____

**2.2. រយៈពេលធ្វើសកម្មភាព/Duration of activity**

2.2.1. ម៉ោងចាប់ផ្តើម/Time started: ____________; 2.2.2. ម៉ោងបញ្ចប់/Time finished:__________

**មតិយោបល់/Remarks:**

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

**3. ការត្រួតពិនិត្យនិងវាយតម្លៃសកម្មភាពការអប់រំ/MONITORING AND EVALUATION OF EDUCATIONAL ACTIVITIES**

**3.1. ខ្លឹមសារសំខាន់ៗនៃមេរៀន/Main content of lessons**

3.1.1. តើឆ្លើយតបនឹងជនគោលដៅបានល្អឬទេ? ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនបាន
How well did it respond to the target audience? Good Medium Weak No

3.1.2. តើឆ្លើយតបនឹងស្ថានភាពគ្រោះថ្នាក់បានល្អឬទេ? ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនបាន
How well did it respond to dangerous situations? Good Medium Weak No

3.1.3. តើបង្ហាញពីលក្ខណៈសម្គាល់យុទ្ធភណ្ឌគ្រឿងផ្ទុះ បានល្អឬទេ? ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនបាន
How well did it tell the characteristic of EO? Good Medium Weak No

3.1.4. តើបង្ហាញពីផលវិបាកនៃគ្រោះថ្នាក់យុទ្ធភណ្ឌគ្រឿងផ្ទុះបានល្អឬទេ? ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនបាន
How well did it tell the impacts of EO accidents? Good Medium Weak No

3.1.5. តើបង្ហាញពីស្លាកសញ្ញាយុទ្ធភណ្ឌគ្រឿងផ្ទុះ(ផ្លូវការនិងក្រៅផ្លូវការ)ឬទេ? ☐ផ្លូវការ ☐ក្រៅផ្លូវការ ☐មិនបាន
Did it tell the indicated EO markings ? Formal Informal No

3.1.6. តើបង្ហាញពីការដាក់ស្លាកសញ្ញាសម្គាល់យុទ្ធភណ្ឌគ្រឿងផ្ទុះបានល្អឬទេ? ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនបាន

How well did it tell how to place EO markings? Good Medium Weak No

3.1.7. តើបង្ហាញពីតំបន់ចម្ការយុទ្ធភណ្ឌគ្រឿងផ្ទុះ បានល្អឬទេ? ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនបាន

How well did it tell the areas of EO fields? Good Medium Weak No

3.1.8. តើបង្ហាញពីឥរិយាបថសុវត្ថិភាពបានល្អឬទេ? ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនបាន

How well did it explain safe behaviours? Good Medium Weak No

3.1.9. តើមានបង្ហាញពីឥរិយាបថមិនសុវត្ថិភាព/គ្រោះថ្នាក់បានល្អឬទេ? ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនបាន

How well did it explain unsafe/dangerous behaviour? Good Medium Weak No

3.1.10. តើបង្ហាញពីវិធីរាយការណ៍ពេលឃើញយុទ្ធភណ្ឌគ្រឿងផ្ទុះ បានល្អឬទេ? ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនបាន

How well did it explain how to report when seeing EO? Good Medium Weak No

3.1.11. តើបញ្ជ្រាបខ្លឹមសារច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវបានល្អឬទេ?

How well did it explain the law on the management of weapons, explosives and ammunition?

☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនបាន

Good Medium Weak No

**មតិយោបល់/Remarks:**

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........

**3.2. វិធីសាស្ត្រនៃការធ្វើបទបង្ហាញ/Methodology of presentation**

3.2.1. ពន្យល់ដោយអធិប្បាយ ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនមាន

Narrative explanation Good Medium Weak No

3.2.2. គ្រប់គ្រងវគ្គ ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនមាន

Course management Good Medium Weak No

3.2.3. បង្ហាញរូបភាព ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនមាន

Using picture Good Medium Weak No

3.2.4. ភាសា និងកាយវិការទំនាក់ទំនង ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនមាន

Language and gesture Good Medium Weak No

3.2.5. និទានរឿងទាក់ទងគ្រោះថ្នាក់យុទ្ធភណ្ឌគ្រឿងផ្ទុះ ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនមាន

Storytelling on EO accidents Good Medium Weak No

3.2.6. ពិភាក្សាជាក្រុមតូចៗ ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនមាន

Group discussion Good Medium Weak No

3.2.7. សម្តែងឈុតឆាកខ្លីៗ ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនមាន

Roleplaying short scenes — Good / Medium / Weak / No

3.2.8. បង្កើត សំណួរ និងចម្លើយ ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនមាន
Questions and answers — Good / Medium / Weak / No

3.2.9. វាស់វែងចំណេះដឹងអ្នកចូលរួមមុននិងក្រោយវគ្គ ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនមាន
Pre test and post test — Good / Medium / Weak / No

3.2.10. សង្ខេបមេរៀន ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនមាន
Lesson summary — Good / Medium / Weak / No

3.2.11. លេងកីឡាឬល្បែងផ្សេងៗ ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនមាន
Game and sport — Good / Medium / Weak / No

3.2.12. ទីតាំងរៀបចំវគ្គ ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនមាន
Course location — Good / Medium / Weak / No

**មតិយោបល់/Remarks:**

.................................................................................................................................................................

.................................................................................................................................................................

.................................................................................................................................................................

**3.3. សម្ភារឧបទ្ទេស/Study materials**

3.3.1. ចំនួនសម្ភារប្រើក្នុងពេលអប់រំ ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនមាន
Quantity of materials used in EORE session — Good / Medium / Weak / No

3.3.2. គុណភាពសម្ភារឧបទ្ទេស ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនមាន
Quality of study materials — Good / Medium / Weak / No

3.3.3. ផ្ទាំងបដា និង គំនូររូបភាពយុទ្ធភណ្ឌគ្រឿងផ្ទុះ ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនមាន
Banners and EO pictures — Good / Medium / Weak / No

3.3.4. ខិតប័ណ្ណ / ប័ណ្ណរូបភាពមីន/គ្រាប់ ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនមាន
Leaflets / posters — Good / Medium / Weak / No

3.3.5. ឧបករណ៍ចាក់សម្លេង ឬ វីដេអូ ឬ ស្លាយ ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនមាន
Audio or video player or slide — Good / Medium / Weak / No

3.3.6. ចែកចាយសម្ភារ ☐ល្អ ☐មធ្យម ☐ខ្សោយ ☐មិនមាន
Distribution of materials/supplies — Good / Medium / Weak / No

**មតិយោបល់/Remarks:**

.................................................................................................................................................................

.................................................................................................................................................................

.................................................................................................................................................................

**3.4. ការរាយការណ៍និងការឆ្លើយតប/ Report and respond**

3.4.1. តើបានបំពេញទម្រង់របាយការណ៍អប់រំដែរឬទេ ? ☐ មាន/Yes ☐ មិនមាន/No

Did you fill EORE report form ?

3.4.2. តើបានសួរ ឬ ទទួលព័ត៌មានយុទ្ធភណ្ឌគ្រឿងផ្ទុះ ថ្មីៗក្នុងតំបន់ដែរឬទេ ? ☐ មាន/Yes ☐ មិនមាន/No

Did you ask or were you informed about new presence of EO ?

3.4.3. តើបានសួរព័ត៌មានពីគ្រោះថ្នាក់យុទ្ធភណ្ឌគ្រឿងផ្ទុះដែរឬទេ ? ☐ មាន/Yes ☐ មិនមាន/No

Did you ask bout EO accident ?

3.4.4. តើបានឆ្លើយតបនឹងសំណើកម្ទេចយុទ្ធភណ្ឌគ្រឿងផ្ទុះដែរឬទេ ? ☐ មាន/Yes ☐ មិនមាន/No

Did you respond to EOD request ?

3.4.5. តើមានតម្រូវការដោះយុទ្ធភណ្ឌគ្រឿងផ្ទុះក្នុងតំបន់ដែរឬទេ ? ☐ មាន/Yes ☐ មិនមាន/No

Was there need for demining/EOD in the area ?

**មតិយោបល់/Remarks:**

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

......

## 4. ការវាយតម្លៃរបស់អាជ្ញាធរមីន/CMAA EVALUATION

☐ **ទទួលយកបាន/Accept** ☐ **មិនអាចទទួលយកបាន/Not accept**

| | |
|---|---|
| *បានពន្យល់សង្ខេបពីការរកឃើញដល់ក្រុមអប់រំ*<br>*Briefly explained the findings to the EORE team* | *ត្រូវបានពន្យល់ពីអាជ្ញាធរមីន*<br>*Was explained by CMAA team* |
| មតិយោបល់ពីអាជ្ញាធរមីន/CMAA comments: | មតិយោបល់ពីប្រតិបត្តិករ/Operator comments:<br>☐ យល់ព្រម/accept ☐មិនយល់ព្រម/not accept |
| ក្រុមត្រួតពិនិត្យ និងវាយតម្លៃ:<br>Monitor and Evaluation Team: | ក្រុមអប់រំ:<br>EORE Team: |
| ឈ្មោះអ្នកត្រួតពិនិត្យ:<br>Name:<br>ភេទ/Sex: | ឈ្មោះប្រធានក្រុមអប់រំ:<br>Name:<br>ភេទ/Sex: |
| ហត្ថលេខា:<br>Signature: | ហត្ថលេខា:<br>Signature: |

ឧបសម្ព័ន្ធ គ/**Annex: C**

# ទម្រង់វាស់វែងចំណេះដឹងអ្នកទទួលសារអប់រំយុទ្ធភណ្ឌគ្រឿងផ្ទុះ

EORE Knowledge Retention Assessment Form

អាជ្ញាធរមីន
C.M.A.A

| |
|---|
| លេខកូដត្រួតពិនិត្យ/ KRA Code: EORE/KRA/CMAA/ |
| កាលបរិច្ឆេទត្រួតពិនិត្យ/Date: |
| លេខក្រុម EORE/Team ID: |
| ការិយាល័យ/Office: |
| ប្រតិបត្តិករ/Operator: |

| 1. ទីតាំងធ្វើការត្រួតពិនិត្យ/Monitoring Location | |
|---|---|
| លេខកូដភូមិ/Village Code: | |
| ភូមិ/Village: ☐ ថ្មី/New | ស្រុក/Distr ☐ ថ្មី/New |
| ឃុំ/Commune: ☐ ថ្មី/New | ខេត្ត/Province: ☐ ថ្មី/New |
| ចំណុចនិយាមការ/GR: អាប់ស៊ីស/X: | អរដោណេ/Y: |

## 2. អ្នកផ្តល់ព័ត៌មាន/Informant:

2.1. ឈ្មោះ/Name:......................................... 2.2. ភេទ/Sex: ☐ ស្រី ☐ ប្រុស 2.3. អាយុ/Age:........ឆ្នាំ

2.4. ☐ពិការ/Person with disability

2.5. លេខទូរស័ព្ទ/Phone number:.........................................................................................

2.6. មុខរបរ/Occupation:.........................................................................................

2.7. អាស័យដ្ឋាន/Address:.........................................................................................

2.8. ស្ថានភាពគ្រួសារ/Family status:

☐ 2.8.1. នៅលីវ/single ☐ 2.8.2. រៀបការ/married ☐ 2.8.3. មេម៉ាយ/ពោះម៉ាយ/ widowed/ divorced

☐ 2.8.4. ចំនួនកូន/child:................ស្រី/female:..............ប្រុស/male:.............

2.9. កំរិតវប្បធម៌/Education:

☐ បឋមសិក្សា/primary education ☐ មធ្យមសិក្សា/secondary education

☐ ឧត្តមសិក្សា/higher education

☐ មិនបានចូលរៀន។ មូលហេតុ/out of school, reason ...................................................

2.10. តើអ្នកបានរស់នៅក្នុងភូមិនេះរយៈពេលប៉ុន្មានហើយ ?/ how long have you lived in this village ?

ខែ/month:........................ ឆ្នាំ/year: ........................

**3. ការយល់ដឹងពីគ្រោះថ្នាក់យុទ្ធភណ្ឌគ្រឿងផ្ទុះ/EO awareness**

3.1. តើអ្នកធ្លាប់បានចូលរួមវគ្គអប់រំកាត់បន្ថយពីគ្រោះថ្នាក់យុទ្ធភណ្ឌគ្រឿងផ្ទុះឬទេ ?

Have you ever attended EORE session ? ☐បាន/Yes ☐មិនបាន/No

- ប្រសិនបើបាន តើនៅឆ្នាំណា ?/if yes, when ?........................................................................................

- ផ្តល់ដោយអ្នកណា ? /who provided EORE session ?............................................................................

- ប្រសិនជាមិនបាន។ មូលហេតុ/if not, reason..............................................................................................

3.2. តើអ្នកស្គាល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែរឬទេ ?/Do you know EO ? ☐ស្គាល់/Yes ☐មិនស្គាល់/No

3.3. តើអ្នកស្គាល់ស្លាកសញ្ញាគ្រោះថ្នាក់យុទ្ធភណ្ឌគ្រឿងផ្ទុះដែរឬទេ ?/Do you know EO marking ?

☐ស្គាល់/Yes

☐មិនស្គាល់/No

- ប្រសិនបើស្គាល់ សូមបញ្ជាក់ ( ផ្លូវការឬក្រៅផ្លូវការ )/if yes, please specify ( formal or informal )

.........................................................................................................................................

3.4. តើអ្នកស្គាល់តំបន់សង្ស័យយុទ្ធភណ្ឌគ្រឿងផ្ទុះ នៅក្បែរភូមិរបស់អ្នកដែរឬទេ ?/Do you know if there suspected hazardous area in your village ? ☐ស្គាល់/Yes ☐មិនស្គាល់/No

3.5. ប្រសិនអ្នកឃើញយុទ្ធភណ្ឌគ្រឿងផ្ទុះនៅកន្លែងណាមួយតើអ្នកធ្វើអ្វីខ្លះ ?/ what will you do if you see EO ?

☐ 3.5.1. មិនប៉ះពាល់វា/don′t touch them

☐ 3.5.2. ដាក់ស្លាកសញ្ញាសម្គាល់កន្លែងគ្រោះថ្នាក់/place warning sign

☐ 3.5.3. រាយការណ៍ទៅអាជ្ញាធរមូលដ្ឋាន ឬប្រតិបត្តករសកម្មភាពមីន/report to local authority or operators

☐ 3.5.4. ធ្វើមិនដឹង/take no action

☐ 3.5.5. ផ្សេងៗ។ បញ្ជាក់/others, please specify:.........................................................................

3.6. តើអ្នកធ្វើអ្វី ? ប្រសិនបើអ្នកឃើញនរណាម្នាក់កំពុងប៉ះពាល់ ឬលេងយុទ្ធភណ្ឌគ្រឿងផ្ទុះ/what will you do if you see someone touching/playing with EO ?

☐ 3.6.1. ណែនាំពួកគេកុំឲ្យលេង/ tell them not to touch/play

☐ 3.6.2. ត្រូវរត់ចេញពីទីនោះ និងប្រាប់ទៅអាជ្ញាធរមូលដ្ឋាន/ run away, and report to local authority

☐ 3.6.3. ផ្សេងៗ។ បញ្ជាក់/others, please specify: ..................................................................

3.7. តើអ្នកធ្វើដូចម្តេច ? ប្រសិនបើអ្នកដឹងថាអ្នកកំពុងស្ថិតនៅក្នុងចម្ការយុទ្ធភណ្ឌគ្រឿងផ្ទុះ/what will you do if you know you are in the minefield ?

☐ 3.7.1. ដើរត្រឡប់ក្រោយតាមដានជើងចាស់/ walk back along previous footsteps.

☐ 3.7.2. ស្រែកហៅអោយគេជួយ/shout out for help

☐ 3.7.3 ផ្សេងៗ។ បញ្ជាក់/others, please specify: ........................................................................

3.8. តើការប៉ះពាល់ ឬផ្លាស់ទីយុទ្ធភណ្ឌគ្រឿងផ្ទុះអាចបង្កគ្រោះថ្នាក់ដែរឬទេ ?

Is it dangerous to touch or move EO ? ☐អាច/yes ☐មិនអាច/no

3.9. តើការយកយុទ្ធភណ្ឌគ្រឿងផ្ទុះមកកែច្នៃ ឬដំលេងមានគ្រោះថ្នាក់ដែរឬទេ ?

Is it dangerous to tamper or hit EO ? ☐មាន/Yes ☐មិនមាន/No

3.10. តើយុទ្ធភណ្ឌគ្រឿងផ្ទុះដែលមានសភាពចាស់ អាចបង្កគ្រោះថ្នាក់ដែរឬទេ ?

Is old EO dangerous ? ☐អាច/Yes ☐មិនអាច/No

3.11. តើអាចប្រើប្រាស់គ្រឿងចក្រធុនធ្ងន់នៅតំបន់ដែលមានការសង្ស័យបានដែរឬទេ ?

Can you use heavy machinery in suspected hazardous areas ? ☐អាច/Yes ☐មិនអាច/No

3.12. តើអ្នកធ្វើដូចម្តេចនៅពេលឃើញថាមានគ្រោះថ្នាក់ក្នុងចម្ការមីន ?

What will you do when you see someone got accident in the minefield ?

☐ 3.12.1. ចូលទៅជួយជនរងគ្រោះថ្នាក់ភ្លាមៗ/ go to help the victims immediately

☐ 3.12.2. រាយការណ៍ទៅអាជ្ញាធរមូលដ្ឋាន ឬភ្នាក់ងារសកម្មភាពមីន/ភ្នាក់ងារជួយជនរងគ្រោះ/report to local authority, mine action operators or victim assistance againcy

☐ 3.12.3. ផ្សេងៗ បញ្ជាក់/others, please specify:……………………………………………………….

3.13. មតិយោបល់/Remarks:

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

**4. ច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ/ Law on the Management of Weapons, Explosives and Ammunition**

4.1. តើអ្នកបានដឹងអំពីច្បាប់អាវុធគ្រឿងជាតិផ្ទុះ និងគ្រាប់រំសេវដែរឬទេ ?

Do you know about law on the management of weapons, explosives and ammunition ?

☐បានដឹង/Yes

☐មិនបានដឹង/No

4.1.1. ប្រសិនជាបានដឹង តើស្ថាប័នណាផ្តល់ការផ្សព្វផ្សាយច្បាប់នេះ ?/if yes, which institution told you about this law ?...........................................................................................................................

4.2. តើការលក់ឬទិញយុទ្ធភណ្ឌគ្រឿងផ្ទុះ ជាទង្វើស្របច្បាប់ដែរឬទេ ?/ Is it legal to sell or buy EO?

☐ស្របច្បាប់/Yes

☐មិនស្របច្បាប់/No

4.3. តើការកែច្នៃតម្លើងមីន/គ្រាប់ជាទង្វើស្របច្បាប់ដែរឬទេ ?/ Is it a legal to tamper mine/ERW?

☐ស្របច្បាប់/legal

☐មិនស្របច្បាប់/not legal

**5. ការវាយតម្លៃទូទៅ/General Evaluation**

5.1. ការវាយតម្លៃរបស់អ្នកធ្វើសម្ភាស អំពីចំណេះដឹងប្រជាពលរដ្ឋក្រោយពីបានទទួលសារអប់រំគ្រោះថ្នាក់យុទ្ធភណ្ឌគ្រឿងផ្ទុះ

Interviewer's assessment of population interviewee's knowledge retention after receiving EORE message

☐ខ្ពស់/high ☐មធ្យម/medium ☐ខ្សោយ/weak

| 5.2. មតិយោបល់/Remarks: |
| --- |
| ........................................................................................................................ |
| ........................................................................................................................ |
| ........................................................................................................................ |
| ........................................................................................................................ |
| ........................................................................................................................ |
| ........................................................................................................................ |

| | |
| --- | --- |
| **លេខសំគាល់អ្នកត្រួតពិនិត្យ**/ ID: | **ក្រុមអប់រំ**/EORE Team: |
| **ឈ្មោះអ្នកត្រួតពិនិត្យ**/Name:<br>**ភេទ**/Sex: | **ឈ្មោះប្រធានក្រុមអប់រំ**/Name of EORE Team Leader:<br>**ភេទ**/Sex: |
| **ហត្ថលេខា**/Signature: | **ហត្ថលេខា**/Signature: |

អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
អគារថ្មី ផ្លូវលេខ២៧៣ កែង៥១៦ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
អ៊ីម៉ែល : info@cmaa.gov.kh
គេហទំព័រ : www.cmaa.gov.kh